មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ជុំ ជាតិ ភេទប្រុស កើតឆ្នាំ១៩៤៨**

**មុខងារសម័យខ្មែរក្រហមៈ យុទ្ធជនកងពល៨០១**

**ស្រុកកំណើតនៅភូមិនៅភូមិចំបក់ស ឃុំ៨មុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ**

**រស់នៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី និង ឌី ខាំបូលី**

**០១:៣៤:០៥**

**៣៦ទំព័រ**

ដានីៈ អីចឹងលោកអ៊ំដឹបូងខ្ញុំចង់ស្គាល់ឈ្មោះលោកអ៊ំ ឈ្មោះពេញ?

ជាតិៈ ខ្ញុំឈ្មោះពេញហ្នឹង ជាតិៈ ជុំ ។

ដានីៈ ឈ្មោះនេះឈ្មោះកំណើតរបស់លោកអ៊ំតែម្តង?

ជាតិៈ មិនមែនឈ្មោះកំណើតទេ ឈ្មោះខ្ញុំធ្វើការតស៊ូក៏ដាក់អីចឹងទៅ ពី៧៩ ។

ដានីៈ ពី៧៩?

ជាតិៈ បាទ!

ដានីៈ ឈ្មោះកំណើតរបស់អ៊ំឈ្មោះអីទៅ?

ជាតិៈ ឈ្មោះកំណើតខ្ញុំឈ្មោះសិទ្ធ ហ៊ន ឈ្មោះខ្ញុំនៅរៀន នៅផ្ទះមុនឆ្នាំ៧០ ។

ដានីៈ ពីឆ្នាំ៧៩ ដូរដាក់ឈ្មោះជាតិៈ ជុំ វិញ?

ជាតិៈ បាទ!

ដានីៈ លោកអ៊ំមានដូរឈ្មោះទៀតដែលអត់?

ជាតិៈ អត់ដូរទេ ដល់សមាហរណកម្មហ្នឹង សម្តេចតេជោហ្នឹងលោកថា ជុំ ជាតិៈ តែម្តងទៅ ក៏សេរេមកដាក់ ជុំ ជាតិៈ វិញ ។ គំនិតខ្ញុំដែលដាក់ ជាតិៈ ជុំ ហ្នឹង ខ្ញុំចង់ថា ខ្ញុំឃើញសភាពការណ៍កន្លងមក ពីឆ្នាំ៧០-៧៩ដូចជាជាតិបែកបាក់គ្នា ខ្ញុំមើលទៅថាអត់សង្ឃឹម អត់ជំនឿពីរឿងថាចងក្រងសាមគ្គីគ្នាបាន ។ សំរាប់ខ្ញុំនឹកឃើញថាសកម្មភាពអី គំនិតអី ធ្វើម៉េចចង់ឲ្យបានជាតិៈយើងរួបរួមគ្នា បានមានឈ្មោះហ្នឹងសំដៅចង់អីចឹង ។

ដានីៈ លោកអ៊ំមកដល់សព្វថ្ងៃនេះអាយុប៉ុន្មានហើយ?

ជាតិៈ ខ្ញុំបើគិតដាក់ស្តែងកើតឆ្នាំ៤៨ ។

ដានីៈ ១៩៤៨?

ជាតិៈ បាទ!

ដានី៖ ស្រុកកំណើតកើតជាលោកអ៊ំនៅណាដែរ?

ជាតិ៖ នៅភូមិចំបក់ស ឃុំ៨មុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

ដានី៖ លោកអ៊ំតាំងពីក្មេងៗមកលោកអ៊ំបានរៀនសូត្រដល់ណាដែរ?

ជាតិ៖ ខ្ញុំរៀនចប់បឋមសិក្សាទេ ។

ដានី៖ ដល់ពេលចប់បឋមសិក្សាហើយលោកអ៊ំ?

ជាតិ៖ ខ្ញុំនៅជាមួយឪពុកម្ដាយធ្វើស្រែ ចំការ ។

ដានី៖ យ៉ាងម៉េចទៀតទៅលោកអ៊ំ?

ជាតិ៖ ដល់ពេលឆ្នាំ៧០មានរដ្ឋប្រហារហ្នឹងក៏ចូលព្រៃម៉ាគីយើងមករហូតតាំងពីឆ្នាំ៧០មក ។

ដានី៖ ចូលព្រៃម៉ាគីយើងតស៊ូ?

ជាតិ៖ បាទ! តស៊ូ ។

ដានី៖ តស៊ូទៅណាខ្លះទៅ?

ជាតិ៖ ខ្ញុំតស៊ូដំបូងធ្វើនៅ កាលហ្នឹងនៅប្រទីប្រទូសត្តខ្ញុំនៅភ្នំឱរ៉ាល់ ទាល់តែឆ្នាំ៧១បានចុះមកធ្វើសកម្មភាពនៅស្រុកកំណើត នៅមុំជុំវិញស្រុកកំណើត ។

ដានី៖ ៧១-៧២-៧៣-៧៤-៧៥ នៅតែមុំឱរ៉ាល់ហ្នឹងឬក៏មានការផ្លាស់ប្ដូរ?

ជាតិ៖ អត់ទេ ចុះមកខត្តុង្គ ធ្វើសកម្មភាពនៅខត្តុង្គ ។

ដានី៖ ដល់ពេល៧៥លោកអ៊ំមកនៅណាវិញ? ពេលបែកភ្នំពេញហើយ?

ជាតិ៖ ពេលបែកភ្នំពេញហើយ៧៦ខ្ញុំនៅរតនគិរី ។

ដានី៖ ទៅដល់រតនគិរី?

ជាតិ៖ បាទ! ទៅរតនគិរី ។

ដានី៖ ទៅខាងកងទ័ព ឬខាងស៊ីវិល?

ជាតិ៖ កងទ័ព ។

ដានី៖ កងទ័ព៨០១?

ជាតិ៖ ៨០១ ខ្ញុំនៅ៨០១ ។

ដានី៖ លោកអ៊ំកាលនៅខាង នៅស្រុកកំណើត នៅខាងខត្តុង្គ នៅក្នុងកងពលណាដែរ?

ជាតិ៖ អត់ទេ មុនដំបូងនៅធ្វើឈ្លប រួចឈ្លបនៅកងពលគេហៅវរសេនា១ ឈ្មោះតាស្រស់ គាត់នៅធ្វើការហ្នឹង ។

ដានី៖ ដល់ពេលឆ្នាំ៧៦លោកអ៊ំត្រូវទៅខាងរតនគិរីវិញ?

ជាតិៈ បាទ! ទៅរតនគិរី ខ្ញុំនៅមុំអូរយ៉ាដាវ កាលហ្នឹងសុទ្ធតែលីចំរៀងច្រៀងអូរយ៉ាដាវដូចថា នេះ ដល់ទៅមើលសុទ្ធតែព្រៃ ។

ដានីៈ លីបទចំរៀងអូរយ៉ាដាវ ។

ជាតិៈ ពីក្មេង កាលហ្នឹងនៅក្មេងដែរ តែព្រៃ ។

ដានីៈ ទៅការពារព្រំដែន?

ជាតិៈ ការពារព្រំដែន ។

ដានីៈ លោកអ៊ំនៅហ្នឹងរហូតដល់បែកឆ្នាំ៧៩ ឬយ៉ាងម៉េច?

ជាតិៈ អត់ទេ មកដល់ឆ្នាំ៧៧គេបញ្ជូនខ្ញុំឲ្យមកនៅក្នុងរ៉ៃគ្នា ផ្ញើសត្រូវម រ៉ៃគ្នាមុំយើងហៅបូព៌ា ។

ដានីៈ អ៊ីចឹងចេញពីកងពល៨០១មកខាងបូព៌ាវិញ?

ជាតិៈ បាទ!

ដានីៈ មកនៅបូព៌ាមកនៅកងពលណាវិញទៅ?

ជាតិៈ មកនៅកងពលកាលហ្នឹងហៅ១៧០ ។

ដានីៈ របស់មជ្ឈិម ឬខាងភូមិភាគ?

ជាតិៈ កាលហ្នឹងរបស់សេនាធិការ ហៅសេនាធិការកាលហ្នឹង ។

ដានីៈ មក១៧០វិញ?

ជាតិៈ បាទ!

ដានីៈ មកនៅ១៧០បានយូរដែរ?

ជាតិៈ មកនៅ៧៧ ដល់៧៨វ៉ៃគ្នារហូត កាលហ្នឹងវ៉ៃគ្នារហូតដល់៧៩ ។ វ៉ៃគ្នាតាំងពី៧៧ នេះខ្ញុំនិយាយជាក់ស្តែង ។

ដានីៈ ១៧០ហ្នឹងកងពលបង្កើតថ្មី ឬយ៉ាងម៉េច?

ជាតិៈ កាលហ្នឹងចាស់ទេ កងពលរបស់សេនាធិការដែរ កាលហ្នឹងគេហៅពាគន្ធាក់ មានទ័ពស្រុក ទ័ពតំបន់, ទ័ពភូមិភាគហៅសេនាធិការ អត់ដូចយើងឥឡូវមជ្ឈិម ហើយបានសេនាធិការ ។

ដានីៈ កងពល១៧០ហ្នឹងមិនមែនកងពលរបស់ ចាន់ ចក្រី ចាស់ទេ?

ជាតិៈ ហ្នឹង ចាន់ ចក្រី ចាស់ខ្ញុំភ្លេចឈ្មោះ ។

ដានីៈ ដល់ក្រោយមកខាងកំពង់ចាមវិញកងពល១៧០?

ជាតិៈ កងពល១៧០វ៉ៃ៧៧ ដល់៧៨អាគេកអាតាក អាញៀអាញៀ មកហ្នឹងក៏ដាច់ដោចគ្នា ៧៩ដាច់ដោចគ្នាមែនទែនហើយ បានខ្ញុំដូរឈ្មោះ ជុំ ជាតិៈ ។ ឃើញអ៊ីចឹងបានពិបាកមែនទែន ។

ដានី: ដល់ពេលវៀតណាមចូលមកឆ្នាំ៧៩ ដែលគេនេះមក ខាងលោកអ៊ំយ៉ាងម៉េចវិញទៅ?

ជាតិ: ចាំមើលខ្ញុំវែក្នាតាំងពីឆ្នាំ ខ្ញុំនៅកំពង់ចាម ដល់នៅអ៊ីចឹង ខ្ញុំកាលហ្នឹងក៏ធ្វើសកម្មភាពដែរ ដល់វៃចូលភ្នំពេញមុនទៅ ខ្ញុំក៏ទាំងអស់គ្នាថាយើងទាល់តែធ្វើសង្គ្រាមឈ្លប តស៊ូយូរអង្វែង ដើម្បីអីៗហ្នឹង ការពារទឹកដីអីចឹងទៅ អីចឹងក៏នាំគ្នាធ្វើសង្គ្រាមឈ្លប ធ្វើរហូតតាំងពី៧៩-៩៣ខ្ញុំនៅកំពង់ចាម ។

ដានី: នៅកំពង់ចាមរហូត?

ជាតិ: ខ្ញុំនៅរហូត ទៅសួរបងប្អូននៅហ្នឹងមើល ។

ដានី: លោកអ៊ំនៅយើងធ្វើប្រតិបត្តិការពីកន្លែងណាដល់កន្លែងណា? ពី៧៩-៩៣?

ជាតិ: ខ្ញុំធ្វើប្រតិបត្តិការពី ខ្ញុំនៅជាប់មែនទែនស្រុកស្ទឹងត្រង់ ។

ដានី: ស្រុកកំណើតខ្ញុំនៅស្ទឹងត្រង់ដែរ ។

ជាតិ: អីចឹង! ក្មួយនៅម្តុំណា?

ដានី: នៅនៅម្តុំដីដុះ ព្រែកសង្កែ ។

ជាតិ: ខ្ញុំធ្វើព្រែកសង្កែ សួរចាស់ៗដឹងហើយ ស្គាល់ខ្ញុំ តាជុំ ខ្ញុំនៅខាងលើម្តុំខ្ពកតាងួន ។

ដានី: ស្រុកកំណើតឪពុកខ្ញុំនៅខ្ពកតាងួន ។

ជាតិ: ឪម៉ាល់ ខ្ញុំធ្លាប់ទៅរកត្រីនៅបឹងឪម៉ាល់, វាលអំពង់, ស្រែអំពៅ ។

ដានី: អីចឹងពី៧៩មកលោកអ៊ំនៅកងពលលេខប៉ុន្មានទៅ?

ជាតិ: ដល់ហ្នឹងគេរៀបចំសារថ្មី កងពលខ្ញុំដាក់កងពល៤១៧ ។

ដានី: ៤៧១មានប៉ុន្មានវរៈទៅ?

ជាតិ: កាលហ្នឹងមាន៤វរៈ ហៅ៧១, ៧២, ៧៣, ៧៤ ។ ហើយខ្ញុំនៅវរៈ៧២ ។

ដានី: អ៊ំនៅវរៈ៧២?

ជាតិ: បាទ!

ដានី: ហើយអ៊ំទទួលខុសត្រូវវរៈ៧២?

ជាតិ: បាទ! ៧២ ។

ដានី: ៧១?

ជាតិ: ៧១កាលហ្នឹងមាន ចង់ភ្លេចហើយយូរពេក ។

ដានី: ខាងកងពល?

ជាតិ: កងពលកាលនោះ អ៊ំកែ ពក, ៧៩ ។ ក្រោយ ទេព ប៉ូច ។ បន្ទាប់មកបានខ្ញុំ ។

ដានី: អ៊ំនៅនេះផង ហើយទទួលនោះទៀត ។

ជាតិៈ អានេះដាក់ស្តែង ។

ដានីៈ ដល់ហើយកងពល៤១៧របស់អ៊ំ យើងធ្វើសកម្មភាពក្នុងខេត្តកំពង់ចាម?

ជាតិៈ បាទ!

ដានីៈ តែក្នុងខេត្តកំពង់ចាមមួយហ្នឹងទេ?

ជាតិៈ កំពង់ចាមផ្នែកខាងលិចទន្លេទៀត ។

ដានីៈ ខាងកំពង់ធំយើងអត់មាននៅទេ?

ជាតិៈ ខាងកំពង់ធំអត់មាននៅទេ ។

ដានីៈ កងពលទាំងមូលអត់មាននៅក្នុងកំពង់ធំទេ?

ជាតិៈ កាលហ្នឹង៧១គេនៅកំពង់ធំ ម្តុំយើងសណ្តាន់ ។ ឥឡូវគេហៅគី តាំងរ៉ែន ។

ដានីៈ ក្រោយខ្ពកតាង៉ួន មកខាងសណ្តាន់ ។

ជាតិៈ ហ្នឹង៧១ គេនៅហ្នឹង ។

ដានីៈ ៧២អ៊ំនៅខាង?

ជាតិៈ នៅស្ទឹងត្រង់ខាងលើ ម្តុំយើងអូរគី ។

ដានីៈ ខាងភ្នំរ៉ៃវ៉ែភ្លុ ។

ជាតិៈ ឆ្ងាយមកដល់ភ្នំក្រហម ។ ដែលលឺភ្នំក្រហមទេ?

ដានីៈ ស្គាល់តែដីក្រហម ។

ជាតិៈ ដីក្រហមផ្សេងហ្នឹងភូមិគេ ដីទួលតែដីក្រហម អាហ្នឹងនៅខាងលិចបេះស្រុកចំការលើ ហើយ
មកដើងស្រុកស្ទឹងត្រង់ ខ្ញុំនៅម្តុំហ្នឹង ។

ដានីៈ ខាង៧៣នៅខាងណាវិញ?

ជាតិៈ ៧៣ម្តុំយើង អត់ដល់បារាយណ៍ទេ ម្តុំបឹងធំ ។ ស្គាល់បឹងធំទេ?

ដានីៈ កងមាស ។

ជាតិៈ នៅភូមិខ្វង់ ជិតចំការលើ ត្រើង ។

ដានីៈ ជិតមកទីរួមខេត្ត?

ជាតិៈ បាទ! ៧៣ម្តុំហ្នឹង ទៅត្បូងទៀត ។

ដានីៈ ដល់ពេល៧៤?

ជាតិៈ ៧៤គេធ្វើនៅម្តុំបារាយណ៍ ជាប់ព្រំប្រទល់បារាយណ៍ ធ្វើការម្តុំហ្នឹង ទៅដល់ព្រៃកុង
កន្លែងធ្វើបាយទឹករាល់ថ្ងៃ ។

ដានីៈ ពេលដែលយើងបែកឆ្នាំ៧៩មក ដូចថាអ៊ំដឹកនាំកងទ័ពយើងមកខាងព្រំដែនឆ្នាំណាទៅ?

ជាតិៈ ដល់ពេលមើល ឆ្នាំ៨០ គេឲ្យមកនៅព្រំដែន គេឲ្យមករៀបចំកងទ័ពដែលចុះធ្វើសកម្មភាព ដូចខ្ញុំនិយាយមុិញ ។

ដានីៈ អីចឹងលោកអ៊ំអញ្ជើញមកដល់ហ្នឹងឆ្នាំ៨១?

ជាតិៈ ត្រឹម៨០-៨១ហ្នឹងឯង ។

ដានីៈ អីចឹងកងពល៤១៧ដែលកើតចេញជាកងពលមក ឆ្នាំប៉ុន្មានទៅ?

ជាតិៈ ៨០-៨១ហ្នឹង ដែលមករៀបចំ ។

ដានីៈ ឆ្នាំ៨០ ចុះមក?

ជាតិៈ ចុង៨០ ដើម៨១ហ្នឹងហើយ ។

បូលីៈ ចុង៨០ហើយ ។

ជាតិៈ ព្រោះ៧៩វិវត្តប្រទូស្ត មិនដឹងអ្នកណាទៅណាៗ ស្របគ្នាហើយបានឆ្នាំ៨០ចាប់ផ្ដើម ។

បូលីៈ រៀបកំលាំងចុះមក?

ជាតិៈ រៀបកំលាងចុះមកក្នុង ។ ហើយកំលាំងខ្ញុំគេចែកជា២ បានជាចែកជា២ព្រោះមួយចំនួនឲ្យនៅព្រំដែន មួយចំនួនចុះមកធ្វើសកម្មភាពឈ្លប ហើយខ្ញុំជាប់ភារកិច្ចមកធ្វើសកម្មភាពឈ្លប

បូលីៈ ពេលដែលចុះមកអីចឹង ឧទាហរណ៍ថាកំលាំងចុះមកមណ្ឌលគិរី តើយើងចែកជាក្រុមតូចៗ ហើយស្រេចហើយចុះមកតំបន់ជាច្រើននៅក្នុងខេត្តមណ្ឌលគិរី ឬយើងចុះមុំធំមកដល់កន្លែងមួយហើយបានយើងចាប់ផ្ដើមបែងចែក យកហ្នឹងធ្វើជាតិតាំងហើយបែងចែកតទៀត?

ជាតិៈ អត់ទេក្មួយ បែងចែកតាំងពីនៅលើហើយ បែងចែកហើយ ឧទាហរណ៍ថាក្មួយនៅទិសណាទៅតាមទិសរៀងខ្លួន ។

ដានីៈ ស្រុកណាត្រូវកងណាទៅ ស្រុកណា តំបន់ណាត្រូវកងណាៗ ដឹងមុខសញ្ញាហើយយើងចុះមកទៅកន្លែងហ្នឹង ទីតាំងហ្នឹង ។

ជាតិៈ ហើយខាងលើចាំតែសួរថាទៅដល់ហើយ មានឧបសគ្គអីអត់ ។

បូលីៈ មិនមែនមួយក្រុមចុះមកក្រចេះ ហើយចាប់ផ្ដើមបំបែកទៅជាក្រុមតូចៗទៅតាមស្រុក ឃុំគេទេ?

ជាតិៈ វាទៅអត់រួចក្មួយ បាញ់គ្នា វិវត្តា ម៉េចទៅរួច ទៅតូចៗ និយាយរួមជ្រាប ។

ដានីៈ អ៊ំមួយទៀត ពេលដែលអ៊ំមានប្រសាសន៍ថានៅខាងស៊ឹងត្រង់ ពេលដែលកងទ័ពទៅអ៊ំទៅស្នាក់នៅកន្លែងណា? ក្នុងព្រៃជាមួយកងទ័ព ឬយើងស្នាក់នៅផ្ទះជាមួយប្រជាជន?

ជាតិៈ កងទ័ពជាមួយខ្ញុំ ខ្ញុំនៅជាមួយកងទ័ព៣៤-១០នាក់ ។

បូលីៈ ក្នុងព្រៃ?

ជាតិៈ ក្នុងព្រៃ នៅព្រៃកៀនៗចំការគេទៅហើយបានបាយ បានទឹក ពីបងប្អូនធ្វើចំការធ្វើស្រែ ។

បូលីៈ ក្នុងមួយក្រុមដែលអ៊ំទៅមានសមាសភាពអីខ្លះ? ឧទាហរណ៍ថាមានពេទ្យ មានតេអូ ឬមានអ្នកកាន់សម្ភារៈ?

ជាតិៈ បើយើងនិយាយពីមានមធ្យោបាយ ដូចយើងរដ្ឋាភិបាល យើងមានពេទ្យមណ្ឌល មានពេទ្យបង្អែក មានដូចគ្នាអីចឹងដែរ ។ ឧទាហរណ៍ដូចយើងអង្គភាព តួនាទីទទួលវរៈ គេមានតេអូ, មានពេទ្យ, កាលហ្នឹងអត់មានទូរសព្ទ គេហៅទូលេខ ។

បូលីៈ គ្រប់ក្រុមមានអីចឹងទាំងអស់ ឬដោយក្រុម?

ជាតិៈ អត់គ្រប់ទេក្មួយ ឧទាហរណ៍អ្នកដែលទទួលតួនាទី ហើយកាលនោះយើងអត់មានអីសំគាល់ទេ មានតែទៅធ្វើ សំគាល់ថាអីចឹង សំគាល់ថាតួនាទីអ្នកឯងធ្វើទៅប៉ុន្មានរួច ។ អត់មានសញ្ញាបត្រដូចឥឡូវសំគាល់ឯណា យើងទៅធ្វើទៅ ។

ដានីៈ ទៅធ្វើតាមជាក់ស្ដែង?

ជាតិៈ តាមជាក់ស្ដែង ហើយធ្វើហ្នឹងចេះទៀត ទៅទៀតតែទៅស្ងាត់ឈឹងគេអត់ជឿយើងដែរ ទាល់តែធ្វើទៅគេឃើញសភាពការណ៍ ទាល់តែខាងយើងនៅភ្នំពេញថាជួបនេះ ជួបនោះ វៃគ្នា បាន ។

ដានីៈ បានខាងលើគេជឿ?

ជាតិៈ បាទ! បានគេទទួលស្គាល់យើង គេតាមដានសភាពការណ៍ខាងយើងដែរ មិនមែនចេះតែឲ្យទៅ បាទៗហើយបាត់ឈឹងទេ ទៅៗទាល់តែទៅមែនទែន ។

បូលីៈ យើងដែលនៅខាងក្នុងយើងរាយការណ៍មកមូលដ្ឋាននេះជាប្រចាំ ឬយ៉ាងម៉េច?

ជាតិៈ រាយការណ៍ជាប្រចាំ មួយថ្ងៃ២ដង ព្រឹកនិងល្ងាច ។

បូលីៈ ចំពោះក្រុមដែលអត់មានសារទូលេខ ឬតេអូ តើមធ្យោបាយក្នុងការរាយការណ៍យើងធ្វើយ៉ាងម៉េច?

ជាតិៈ ឧទាហរណ៍ថាយើងទៅ១០នាក់ ថាទៅត្រពាំងប្រាសាទ ១០នាក់ទៅព្រឹកដែនការ ល្ងាចឡើងមកវិញរាយការណ៍ថាទៅធ្វើអីៗ ។

បូលីៈ ហ្នឹងសំរាប់ក្រុមដែលមានសារទូលេខ?

ជាតិៈ ទេ ចង់និយាយថាអ្នកដែលមាន គេថាមានហើយ គេបែកគេមានកំលាំង ។ ឧទាហរណ៍ថា៣០នាក់អីចឹងទៅ ឬ២០នាក់ គេឲ្យទៅធ្វើសកម្មភាព ទៅធ្វើសកម្មភាពទៅដឹងហើយ ទៅដល់ណា? ទៅជួបអីខ្លះ? ហើយជួបប្រជាជនទឹកចិត្តប្រជាជនយ៉ាងម៉េច? ចេះតែសួររឿងប្រជាជនសំខាន់ៗ ប្រជាជនស្រឡាញ់ ស្អប់ ខាងយើង ខាងយួន?

បូលីៈ ពេលដែលយើងទទួលកិច្ចការពីនេះទៅ ចង់ដឹងក្នុងមូលដ្ឋានធ្វើការមូលដ្ឋាន អ្វីដែលជាកិច្ចចំបងរបស់ក្រុមនីមួយៗ?

ជាតិៈ ក្រុមនីមួយៗ បើក្រុមខាងខ្ញុំទៅធ្វើសកម្មភាពគេហៅតំបន់ឈ្លបហ្នឹង សំខាន់គឺអប់រំនយោបាយហ្នឹងទី១ ។

ដានីៈ អប់រំនយោបាយជាគោលការណ៍ពីលើមកដាក់ថាយើងត្រូវអប់រំយ៉ាងម៉េចៗ មានជាលាយលាក់អក្សរដែរ?

ជាតិៈ គ្រាន់តែបង្រៀនប្រាប់យើង យើងយល់ទៅមានអីលំបាក។ ខួរក្បាលយើងគឺថា គេមានឯកសារដែរ នយោបាយ ដង់ស៊ីតេ?

បូលីៈ អ៊ំអាចជួយលំអិតបានទេ?

ជាតិៈ លំអិតខ្ញុំអត់ចាំច្បាស់ គ្រាន់តែខ្ញុំធ្វើតាមខ្ញុំធ្លាប់ធ្វើ ។ ទៅគឺថាយើងទៅតំបន់ហ្នឹង គឺរៀបចំមូលដ្ឋានឈ្លប ។ កាលហ្នឹងគេបង្រៀនខ្ញុំ គឺយើងលប ពាក្យថា«យើងលប» ទៅធ្វើការងារប្រជាជន ។

បូលីៈ លបទៅធ្វើការងារប្រជាជន បានន័យថាម៉េច?

ជាតិៈ ចុះគេខាងយើងមិនយួនទាហានវៃ បើវៃយើងទៅចំហរម៉េចបាន ទាល់តែលបយើងលប ។

បូលីៈ ទៅអប់រំប្រជាជន?

ជាតិៈ អប់រំប្រជាជន ។

ដានីៈ យើងអប់រំថាម៉េចខ្លះទៅ?

ជាតិៈ អប់រំថាច្រើនណាស់ក្មួយ ។

ដានីៈ ថាជាសង្ខេប?

ជាតិៈ តែនេះខ្ញុំនិយាយជាក់ស្តែងកាលនោះទេក្មួយ មិនមែននិយាយឥឡូវទេ និយាយឥឡូវអត់បានទេ និយាយកាលនោះ ។ ទៅការពារសុវត្ថិភាព ។

ដានីៈ អត់អី ។

ជាតិៈ អេអត់អីម៉េច ក្រែងលោអី ក្មួយទៅបាត់ ។ អាហ្នឹងចង់និយាយថាអីចឹង អានេះសុទ្ធតែថត ឥឡូវខ្ញុំសុំបញ្ជាក់ ខ្ញុំនិយាយកាលនោះ ខ្វាចល័សុវត្ថិភាពរបស់ខ្ញុំ ។

បូលីៈ អាចបិទប្រដាប់ថត ។

ជាតិៈ ចង់ឲ្យច្បាស់អីចឹង ទទួលខុសត្រូវ បើនិយាយទៅវាប៉ះពាល់សុវត្ថិភាព ។

បូលីៈ អានេះយើងនិយាយពីអតីតទេ ។

ជាតិៈ អតីតៗ ដល់ពេលហើយទៅវាមិនទៅជាអតីត វាទៅជាបច្ចុប្បន្នវាគ្រោះថ្នាក់ខ្ញុំ ជីវិតថាងាប់តាមដំណើរ កុំឲ្យវាងាប់ខុសដំណើរ ។ ឥឡូវយ៉ាងម៉េច?

ជានីៈ ពីអតីតខ្ញុំចង់ដឹង ។

ជាតិៈ អតីតដែល តែឧបមាថាគេច្នៃថាខ្ញុំ វាលំបាកណាស់ ។

បូលីៈ បិទសំលេងមួយរយៈ ចង់ដឹងពីកន្លែង ។ ការស្រាវជ្រាវនេះក៏រដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជននេះអនុញ្ញាតឲ្យធ្វើដែរ ព្រោះគាត់យល់ថាហ្នឹងមានតម្លៃនៅក្នុងការអប់រំទូទៅ ។ អីចឹងយើងរំលងហ្នឹងបន្តិច យើងទៅប្រធានបទផ្សេង ។

ជាតិៈ អីចឹងបានន័យថាខ្ញុំចូលក្នុងប្រធានបទដែលក្មួយចង់បញ្ជាក់ថាខ្ញុំតើធ្វើស្អីៗ អាមួយធំខ្ញុំអត់និយាយស្ទើស បើនិយាយទៅវាសុវត្ថិភាពដល់ខ្ញុំ ។ ខ្ញុំនិយាយពីបញ្ហាមួយទៀតដែលពួកខ្ញុំយកចិត្តទុកដាក់ គឺគិតគូរដល់សុខទុក្ខប្រជាជន ប្រជាជនគាត់ត្រូវការអី ខ្វះខាតអី ហើយប្រជាជនត្រូវរងគ្រោះពីចោរលួច ចោរប្លន់អីខ្ញុំការពារ និយាយរួមបម្រើប្រជាជន ។ បើអត់ត្រូវប្រជាជនម៉េចនៅបានក្មួយ តាំងពី៧៩-៩៣ ប៉ុន្មានឆ្នាំ ។

បូលីៈ ១៤ឆ្នាំ ។

ជាតិៈ បាទ! ១៣ឆ្នាំនៅហ្នឹងជាមួយប្រជាជន ។

ជានីៈ ហើយកំលាំងចេះតែកើនឡើងដែរ ។

ជាតិៈ កើនឡើង ។

ជានីៈ ហើយទី៣? មុញទី២ គិតពីសុខទុក្ខប្រជាជន ។

ជាតិៈ ហើយទី៣ យើងបំផុសប្រជាជនឲ្យបង្កបង្កើនផល ឧបត្ថម្ភខ្លួន ឲ្យគាត់ខំប្រឹង មានដីធ្លីហែកដី ហែកធ្លី ធ្វើម៉េចឲ្យមានហូប មានចុក ដល់ពេលទី៤បំផុសការឧបត្ថម្ភ ឲ្យគាត់ឧបត្ថម្ភយើង ។

បូលីៈ មកកំលាំងយើង?

ជាតិៈ ជាតិៈញថៅកៗ ។ ពេលខ្លះពួកខ្ញុំទៅបោកស្រូវ ទៅប្រូត ធ្វើជាមួយគាត់ទៅ គាត់អត់បានយកទៅផ្ទះទេ ឃើញយើងធ្វើគាត់អាណិត លាក់នឹងព្រៃកយើងហូបផង គាត់ហូបផងស្រុកស៊ីងគ្រង់ខ្ញុំហូបបាយតែហ្នឹង ។

បូលីៈ ដែលពើកប្រទះជាមួយនឹងទាហានខាងរដ្ឋាភិបាលខាងក្នុង ឬទាហានយួនទេពេលហ្នឹង?

ជាតិៈ រាប់អត់អស់ ។

បូលីៈ ច្រើន?

ជាតិៈ បាទ! រាប់អត់អស់ក្អួយ បើនិយាយរឿងប៉ះរាប់អត់អស់ ។ គ្រាន់តែថាប្រជាជនល្អណាស់ ខ្ញុំនិយាយដល់ហ្នឹងប្រជាជនល្អណាស់ កាលនោះវៀតណាម យួនចេញមកទីណា ៗគាត់ប្រាប់ ។ គេមកយើងកុំទៅ ។

ដានីៈ កាលជំនាន់ហ្នឹងអ៊ំធ្លាប់ប៉ះជាមួយទាហានខាងខេត្តកំពង់ចាមដែរ? កងទ័ពរបស់រដ្ឋាភិបាល

ជាតិៈ ម៉ៅ ភារុណ ប៉ះឆ្អែតហើយ គាត់ឡើងទៅវៃខ្ញុំ ខ្ញុំនៅភ្នំគាត់ដឹងដែរ ។ គាត់ស៊ើបការណ៍ពីខ្ញុំ ខ្ញុំក៏ស៊ើបការណ៍ពីគាត់ វៃគ្នា ពីដើមរកស៊ីកៅស៊ូ ។

ដានីៈ ម៉ៅ ភារុណ, ងឹល រីម?

ជាតិៈ បាទ ។

បូលី ស្គាល់ឈ្មោះគ្នាច្បាស់អីចឹងម៉ែហពេលហ្នឹង?

ជាតិៈ លឺតែឈ្មោះ តាមដានសួរ កងទ័ពនេះ កង៣៣, ៣២ ។ យើងសួរកងណាមក សួរទាល់តែដឹង ។

ដានីៈ មានអាវុធ?

ជាតិៈ មានកំលាំងអាវុធ, មានឌីបេ ។

បូលីៈ ពេលដែលចុះទៅធ្វើការហ្នឹង អ៊ំមានសង្ឃឹមទេពេលហ្នឹង ពេលដែលបានជួបប្រទះជាមួយទាហានខាងក្នុង ទាហានយួន? អប់រំប្រជាជនទៅមានសង្ឃឹមទទួលបានផលនៅក្នុងចិត្តអ៊ំ?

ជាតិៈ ក្នុងចិត្តខ្ញុំបើនិយាយអីចឹង ខួរក្បាលសង្ឃឹមតែម្តង ។ សង្ឃឹមថាស្អី? ថាការពារជាតិៈ ការពារទឹកដីឲ្យបានមិនឱបដៃឈរស្ងៀម គឺរួមជាមួយជាតិៈ ប្រជាជនដើម្បីការពារទឹកដី ។ សង្ឃឹមការពារទឹកដី អត់មានសង្ឃឹមថាទៅកាន់អំណាចអីទៀតទេ អត់កាន់អំណាចបានទេ ។ អីចឹងហើយបានពួកខ្ញុំខំតស៊ូ ដើម្បីឲ្យមានកិច្ចព្រមព្រៀងប៉ារីស ឲ្យយួនព្រមដកទ័ព ហើយយើងមានពហុបក្ស ចង់បានតែប៉ុណ្ណឹងទេ ។ ឥឡូវសួរគេណាណើទៀតមិនដឹងទេ តែសំរាប់ខ្ញុំខួរក្បាលគឺចាំអីចឹងតែម្តង រហូតដល់ថាចេះទៀត សភាពការណ៍នេះយើងមិនអាចកាន់អំណាចបានទេ យើងធ្វើម៉េចឲ្យតែបានភូមិ-ឃុំ ហើយយើងបោះឆ្នោតទៅ អ្នកណាស្រឡាញ់បោះឆ្នោតឲ្យអ្នកហ្នឹងទៅ ។

បូលីៈ ដឹងដែលអីចឹង?

ជាតិៈ គោលការណ៍ដឹងអាហ្នឹងបានខំប្រឹងធ្វើ កុំអីទៅចោលបាត់យូរហើយ ទៅស្រុកទេសបាត់ហើយ ដឹងអាហ្នឹង ចង់បានបោះឆ្នោត ។

ដានីៈ តែពីគោលការណ៍ពីអ៊ំ ៗខាងលើ ពេលដែលរៀនសូត្រ ទស្សនៈ គោលជំហររបស់គាត់ គាត់គិតដូចអ៊ំដែរ ឬគាត់គិតផ្សេងពេលដែលគាត់ណែនាំ?

ជាតិៈ	គាត់គិតអីចឹងហើយបានគាត់មកបង្ហាត់ខ្ញុំអីចឹង គាត់ថាអីចឹងយើងអត់បានទេ ហើយគាត់ប្រៀបធៀបដូចនៅអ៊ឺរ៉ុប យើងធ្វើឲ្យល្អប្រហែលប៉ុន្មាញ។ ប៉ុន្មាញគេចេះបង្រួបបង្រួមផ្ទះផ្សារ បោះឆ្នោត និយាយរហូត។ យើងចេញពី៩៣ធ្វើកសិកម្ម ធ្វើសេដ្ឋកិច្ច ធ្វើយ៉ាងម៉េច បង្រៀនរហូតយើងដាំចំការដី២គីឡូ ហើយដីនៅផ្ទះយើងអត់ល្អ ប្រៀបធៀបទៅដាំនៅចំការ២គីឡូដើរទៅចំការ ហើយដីយើងអត់ល្អ យើងសុខចិត្តដាំធ្វើដីតិចៗផងវែក១-២អំវែកដីល្អដាំបន្លែ គ្រាន់តែចង់សួរបេះទៅ រៀនតែអីចឹងឯង។

បូលីៈ	អ្នកណាអ្នកបង្រៀនហ្នឹង?

ជាតិៈ	តាប៉ុល ពត។

បូលីៈ	តាប៉ុល ពត គាត់នៅខាងកោះកុង ត្រាប?

ជាតិៈ	កាលហ្នឹងពួកខ្ញុំទៅរៀននៅហ្នឹង ដល់ហើយគាត់នៅអន្លង់វែង។

ដានីៈ	អន្លង់វែងក្រោយ៩៣ហើយបានគាត់អញ្ជើញមក?

ជាតិៈ	ក្រោយ៩៣។

ដានីៈ	ពីមុន៩៣គាត់នៅណា?

ជាតិៈ	ពីមុនក៏រៀនអីចឹង។

ដានីៈ	អីចឹងពេលដែលទៅរៀនយើងចុះទៅធ្វើសកម្មភាពនៅតាមខាងក្នុងហ្នឹង ដល់ពេលថ្ងៃខែត្រូវរៀន យើងទៅទាំងអស់។

ជាតិៈ	អត់ទៅទាំងអស់គ្នា ទៅតែមេៗ។

ដានីៈ	ឋានៈចាប់ពីត្រឹមណាទៅដែលត្រូវទៅរៀនជាមួយគាត់?

ជាតិៈ	ថ្នាក់កងវរៈ។

ដានីៈ	វរសេនាធំ ឬវរសេនាតូច?

ជាតិៈ	ខ្ញុំថា៧១, ៧២។

ដានីៈ	វរសេនាធំទៅ។

បូលីៈ	ទទួលការអប់រំ ណែនាំ។ នៅ១០០១នេះ តាសុន សេន ដែលបង្រៀនទេ?

ជាតិៈ	គាត់បង្រៀន ខ្ញុំដែលនៅស្ទិទហើយស្គាល់តែតាសុន សេន។ ខ្ញុំស្គាល់តាំងពីឆ្នាំ៧៣ គាត់នៅសេនាធិការ ឆ្នាំ៧៣ខ្ញុំស្គាល់។

ដានីៈ	គាត់ចុះទៅខាងតំបន់១៥ ខាងភូមិភាគពិសេស។

ជាតិៈ	បាទ! ភូមិភាគពិសេស ខ្ញុំស្គាល់គាត់ឆ្នាំ៧៣។

បូលីៈ	អីចឹងបានន័យថាមូលដ្ឋានអ៊ំ គឺចេញពី១០០១ចុះទៅធ្វើការខាងក្នុង កងពល៤១៧ហ្នឹង?

ជាតិៈ បាទ ។

បូលីៈ ពេលដែលវៀតណាមវៃចូលចុង៨៤ ដើម៨៥ កងទ័ពវៀតណាម និងកងទ័ពរដ្ឋាភិបាលរដ្ឋកម្ពុជាខាងក្នុងធ្វើប្រតិបត្តិការបោសសំអាតខ្មែរក្រហមនៅតាមព្រំដែនទាំងអស់ មិនអីចឹងអ៊ំ?

ជាតិៈ បាទ!

បូលីៈ ពេលហ្នឹងយើងរុញមកដីថៃហើយពេលហ្នឹង?

ជាតិៈ បាទ!

បូលីៈ អ្នកនៅខាងក្នុងបន្តធ្វើសកម្មភាពទៅ?

ជាតិៈ បាទ!

បូលីៈ តែអ្នកទល់ដែនគឺមកដីថៃអស់ហើយ?

ជាតិៈ បាទ!

បូលីៈ ពេលហ្នឹងតំបន់១០០១ត្រូវរលំ ហើយទៅណាទៀតទៅពេលហ្នឹង?

ជាតិៈ ពេលហ្នឹងមកនៅដងទង់ មកច្រកយើងអន្លង់វែង ។

បូលីៈ ១០០៣នេះវិញ?

ជាតិៈ បាទ! ១០០៣ ។

ដានីៈ កន្លែងស្អីគេទៅដងទង់?

ជាតិៈ ដងទង់ដីថៃ ។ តែគេហៅក្បាលស៊ីងច័ន្ទ ។

បូលីៈ ចន្លោះប៉ុន្មានគីឡូពីដីខ្មែរ ព្រំដែនដីខ្មែរយើងទៅអ៊ំ?

ជាតិៈ ប្រហែលជា អត់ចាំច្បាស់ទេ ដើរព្រៃអត់គិតដែនទី ខ្ញុំអន់បំផុតក៏១៥គីឡូដែរ ។

ដានីៈ ពីព្រំដែនយើងចូលទៅក្នុងទឹកដីថៃប្រហែលជា១៥គីឡូ?

ជាតិៈ ខ្ញុំសុំស្មានទេ អត់បានមើលដែនទីស្រួលបួល ព្រោះខ្ញុំដើរយូរដែលទំរាំមកដល់ ។

បូលីៈ សាច់ដើរប៉ុន្មានម៉ោងអ៊ំបើយើងគិតទៅ?

ជាតិៈ ដើរអត់ត្រង់ ដើរកន្លែងខ្លះដើរវៀង ។ ដើរគេចថៃផង ដើរគេចយើងផង ។

ដានីៈ អីចឹងពេលទៅអីចឹង១០០១ លែងមានទៀតហើយ?

ជាតិៈ លែងមានទៀតហើយ ។

បូលីៈ ក្រុម១០០១ដែលមក១០០៣ តើនៅតែបន្តស្ថិតក្រោមការគ្រប់គ្រងរបស់តាសុន សេន ឬមកក្រោមទ័ពវិញហើយ?

ជាតិៈ ដោយឆ្នាំ៩៣យើងមានការប្រែប្រួលខ្លួយ ប្រែប្រួលរៀបចំឲ្យតាសុន សេន, តាខៀវ សំផន ហ្នឹងមកចូលក្នុងគេហៅថា ត្រីភាគី ដល់អីចឹងពួកខ្ញុំនេះទាំងអស់ក៏ថា តាសុន សេន គាត់ទៅនោះហើយ កាលហ្នឹងគេចែកការងារជាពីរ ។ ចែកការងាររណសិរ្សមួយ, ចែកការងារមូលដ្ឋានមួយ ។

ជានីៈ ពីឆ្នាំណា?

ជាតិៈ ឆ្នាំ៩១ កិច្ចព្រមព្រៀងប៉ារីស សេរ៉ើឲ្យត្រូវគ្នា ។

ជានីៈ តែមុនឆ្នាំ៩១ ពេលដែលខាងវៀតណាម ពេលរដ្ឋកម្ពុជាវ៉ៃយកបាននេះ ខ្វង់ឆ្នាំ៨៤-៨៥?

ជាតិៈ បែបប៉ុណ្ណឹងឯង ។

ជានីៈ តែ៨៤-៨៥ ពេលដែលយើងទៅក្បាលស្ទឹងចាន់ តាសុន សេន គាត់នៅគ្រប់គ្រងហ្នឹងនៅឡើយ?

ជាតិៈ គ្រប់គ្រង ។

បូលីៈ រហូតដល់ឆ្នាំប៉ុន្មានបានគាត់ទៅរណសិរ្ស តាសុន សេន?

ជាតិៈ មើលប្រជុំប្រកាស ទាល់តែ ៩៣ហ្នឹងឯង ខ្វង់កៅជាង ។

បូលីៈ ព្រោះបើយើងគិតអំពីដំណើរការនៃការចរចារ ។

ជាតិៈ ឲ្យត្រូវដំណើរការចរចារព្រោះធ្វើស្របគ្នាដែរ ។

បូលីៈ ៩១យើងសន្តិភាពហើយ យើងមានហត្ថលេខា ។

ជាតិៈ ខ្ញុំសុំគាត់មួយ រឿងដែលថាគាត់ចេញយើងកិច្ចព្រមព្រៀងហៅអ៊ុនតាក់ហ្នឹងគេចុះនៅមើល យើងចែកគ្នាអីចឹង យើងញែកទៅខាងហ្នឹង ទ័ពណាត្រូវនៅត្រង់ណា រាប់ទាំងខ្ញុំដងអត់បាន ឈ្មោះនៅក្នុងហ្នឹងទេ ឈ្មោះចូលក្នុងការងារកិច្ចព្រមព្រៀងប៉ារីសទេ ហ្នឹងថ្ងៃហ្នឹង ថ្ងៃយើងមានទ័ពខាងនេះ ខាងនោះ ភាគីទៅ ខ្មែរក្រហមទៅ អាហ្នឹងទៅចែកគ្នាអីចឹងហើយ ។ ហើយខ្ញុំមកតាម៉ុក គ្រប់គ្រងហើយ ។

បូលីៈ គេប្រកាសអីចឹងតែម្តង គេមានធ្វើពិធីប្រកាសតាសុន សេន ទៅរណសិរ្សហើយយើងត្រូវមកក្រោមតាម៉ុក?

ជាតិៈ គេប្រជុំ ខ្មែរក្រហមខស្សាប់ប្រជុំណាស់ ប្រជុំញឹកណាស់ ។

ជានីៈ ប្រជុំនេះយើងដឹងតែមេៗថ្នាក់វរសេនាធំ ថ្នាក់កងពល ក៏ប្រជុំទូទៅជាមួយប្រជាជន?

ជាតិៈ អត់ទេ ប្រជុំតែមេៗ ហើយមេៗចុះមកតាមអង្គភាពប្រជុំតគ្នាទៀតទៅ គិតទៅ៣-៤តន្ទាក់ ។ ហើយកិច្ចការហ្នឹងអ្នកណាធ្វើអីគេដឹងហ្នឹង ហើយអ្នកណាអត់ធ្វើអីអត់ដឹងទៅ

ហើយគេប្រជុំ គេរើសមនុស្សទៀត អ្នកណាគួរនិយាយបាន អ្នកណាអត់គួរនិយាយ អ្នកដែលអត់គួរ និយាយគេអត់និយាយទៀត ធ្វើធម្មតាទៅ ទុកជាកំលាំងទាំងអស់គ្នា គេបែងចែកម៉ត់ចត់ណាស់ ។ នេះអ៊ំនិយាយឲ្យច្បាស់តែម្តង គេបែងចែកម៉ត់ចត់ណាស់ មិនមែនចេះតែប្រឡូកប្រឡាក ហើយមុននឹងនិយាយអីគេត្រូវគិតថានិយាយពាក្យអី ប្រធានបទអី ។

បូលីៈ ខ្ញុំបើតាមស្តាប់ប្រសាសន៍អ៊ំ ពូ មីង ដែលខ្ញុំបានសម្ភាសន៍គាត់មក យើងឃើញថាកំលាំងរបស់ខ្មែរក្រហមនៅតាមព្រំដែនមានច្រើនចំណុចណាស់ ពីមួយជួរនេះរហូតដល់នេះវាមានជាង៨០០គីឡូម៉ែត្រ អីចឹងវាមានច្រើនដែលបែងចែកឈរនៅតាមព្រំដែន ។ ខ្ញុំអាចសន្និដ្ឋានបានថាកំលាំងដែលធំជាងគេគឺនៅ១០០៣ ។ កំលាំងធំហើយច្រើនជាងគេនៅ១០០៣ ក្រោមការគ្រប់គ្រងរបស់តាម៉ុក ។

ជាតិៈ ថាអីចឹងក៏បាន ព្រោះកំលាំង១០០៣រួមទាំង១០០១ផង ដូចធំដែលរួមទៅហើយ ។

បូលីៈ អីចឹងពី៨៥មកដល់យើងចរចារសន្តិភាព៩១ តាសុន សេន និងតាម៉ុក គាត់នៅនេះសិន មិនទាន់ចេញទៅ ឬគាត់ចេញមុន?

ជាតិៈ ទៅហើយ ។

បូលីៈ អីចឹងតាម៉ុក គាត់គ្រប់គ្រងទាំងអស់ កំលាំងដែលនៅទីនេះ?

ជាតិៈ បាទ! កំលាំងដែលខ្ញុំនិយាយឲ្យអស់ទៅ មិនមែនថាអួតអាងទេ ដែលធ្វើសកម្មភាពហ្នឹងគឺអីគឺយកកំលាំង១០០១មកធ្វើ ដូចជាវ៉ៃផ្លូវ១២ ពួកខ្ញុំគេឲ្យវ៉ៃ ដូច្នេះខ្ញុំយកកំលាំងមកគឺថាកំលាំងទាំងដុល ហើយតាចេះតែបញ្ជាទៅ ទៅធ្វើនេះ ធ្វើនោះ ។ ឥឡូវសួរបងប្អូនទាំងអស់គ្នា អ្នកណាក៏ដឹង ខ្ញុំនិយាយតែការពិត អីចឹងឯង ។

បូលីៈ ផ្លូវ១២ចាក់ពីណាទៅណា?

ជាតិៈ ផ្លូវ១២យើងចាក់ពីព្រះវិហារទៅកំពង់ធំ ។

ដានីៈ អ៊ូ! ផ្លូវព្រះវិហារ?

ជាតិៈ បាទ! ផ្លូវព្រះវិហារ ។

ដានីៈ ផ្លូវខេត្តព្រះវិហារ គាត់មកកំពង់ធំ-កំពង់ស្វាយ!

ជាតិៈ គោលបំណងយើងចង់យកខេត្តព្រះវិហារទេ យកប្រាសាទ យកខេត្តព្រះវិហារ ។

បូលីៈ ពេលហ្នឹងប្រាសាទព្រះវិហារនៅក្រោមការគ្រប់គ្រងរបស់ខាងកំលាំងខ្មែរក្រហម ឬកំលាំងរដ្ឋាភិបាលខាងក្នុង?

ជាតិៈ កំលាំងខ្មែរក្រហម ។

បូលី៖ ប្រាសាទព្រះវិហារ?

ជាតិ៖ បាទ! ខ្ញុំដើរពីនេះទៅដេកផ្លូវ១យប់បានដល់ ។

ដានី៖ ឆ្នាំណាដែលអ៊ំដើរពីហ្នឹងដល់ព្រះវិហារ?

ជាតិ៖ ខ្ញុំទៅឆ្នាំ៩៣-៩៤ហ្នឹង ដែលវៃដណ្តើមគ្នាចុះឡើងៗ ។

ដានី៖ ចុះមុនហ្នឹងអ៊ំ កាលពីពេលយួនទៅ?

ជាតិ៖ យួនទៅ ។

បូលី៖ ព្រះវិហាររបស់យើង ឬរបស់យួនកាលហ្នឹង?

ជាតិ៖ កាលពីហ្នឹងយួនទៅយើងវៃយកបានមកវិញ ។

ដានី៖ យើងវៃយកបានឆ្នាំណាទៅ?

ជាតិ៖ មុន៩៣ហ្នឹងឯង ។

បូលី៖ វៃយកបាន?

ជាតិ៖ បាទ! តាំងពី៩១-៩២ ។

ដានី៖ ពេលដែលតាសុន សេន គាត់ត្រូវទៅកាន់ខាងរណសិរ្សវិញ ហើយក្រោយមកកំលាំងទាំងអស់ទាំង១០០១, ១០០២, ១០០៣ នៅក្រោមការគ្រប់គ្រងរបស់តាម៉ុក?

ជាតិ៖ បាទ! របស់តាម៉ុក ។

ដានី៖ ពេលហ្នឹងកងកំលាំងទាំងអស់ហ្នឹងត្រូវរ៉ូវគ្នា សហការណ៍គ្នាបានល្អដែរ ឬចាប់ផ្តើមមានបញ្ហាដោយប្រការណាមួយមានដែលអត់ ពេលដែលបន្ទាប់ពីតាសុន សេន ចេញទៅ?

ជាតិ៖ ខ្ញុំអត់បានឃើញ ធម្មតាទេក្មួយអើយ មនុស្សតែងតែមាន ឧទាហរណ៍ថាតាម៉ុក គាត់ស្គាល់ ធ្លាប់នៅជាមួយពីមុនមក ហើយពួកខ្ញុំ១០០១ធ្លាប់នៅក្រោយ ការប្រាស្រ័យទាក់ទងគ្នា ការស្និទស្នាលវាមានអីចឹងធម្មតា ច្បាប់កងវរៈ ។

បូលី៖ វាមានគំលាតជាងអ្នកដែលនៅក្បែរពីមុន?

ជាតិ៖ ធម្មតាមនោសញ្ចេតនាវាមានអីចឹង តែឲ្យទាស់បែកបាក់គ្នាអត់មានទេ គ្រាន់តែថាធ្លាប់ស្គាល់គ្នាក៏ជាងទៅ ហើយយើងអត់ធ្លាប់ស្គាល់ក៏ប្រយ័ត្នប្រយែង និយាយរួមប្រយ័ត្នប្រយែងខ្លាច ។

ដានី៖ ខ្លាចគាត់ដែរ?

ជាតិ៖ រឿងខាងនោះគេខ្លាចណាស់រឿងវិន័យ និយាយរួមវិន័យតែម្តង ខ្លាចវិន័យ គោរពវិន័យ ។

| | |
|---|---|
| បូលីៈ | មុនដែលយើងចុះមកអន្លង់វែង-ត្រពាំងប្រាសាទ យើងចុះមកឆ្នាំ៩០? ដែលយើងវៃបានទីតាំងអន្លង់វែង-ត្រពាំងប្រាសាទ នាំគ្នាចុះមកខាងក្រោម ។ មុនដែលយើងចុះមកទាំងកងទ័ព ទាំងគ្រួសារកងទ័ព ប្រជាជននៅខាងដីថៃ? |
| ជាតិៈ | បាទ! នៅដីថៃ ។ |
| បូលីៈ | ការផ្គត់ផ្គង់សម្ភារៈ ស្បៀងអាហារ បានមកតាមរបៀបណា? |
| ជាតិៈ | ក្នុយ បើក គេបើកអង្ករ, ខោអាវ, សំលៀកបំពាក់ ។ |
| បូលីៈ | របបគេចែកយ៉ាងម៉េចដែលកាលហ្នឹង? |
| ជាតិៈ | ខោអាវ២កំប្លេ១ឆ្នាំ ក្រណាត់៤ម៉ែត្រ ដោយឆ្នាំ ហើយបីចេង និយាយរួមជីវភាពបើកតែដល់មកក្រោមហើយអត់ទ័ពអត់បើកឲ្យទេ ធ្វើស្រែ ធ្វើចំការហូបខ្លួនឯង ។ |
| ដានីៈ | ហ្នឹងទាល់តែទ័ពបានបើកឲ្យ? |
| ជាតិៈ | ទ័ពបើកឲ្យ ។ |
| ដានីៈ | បើថាប្រជាជន គ្រួសារកងទ័ពអីហ្នឹងយើងធ្វើស្រែ ធ្វើចំការខ្លួនឯង? |
| ជាតិៈ | ឲ្យខំធ្វើស្រែ និយាយរួមមានធ្វើស្រែគ្រប់តែអន្តភាព ទិញអាត្រាក់ឲ្យ ភ្ជួរទៅ ។ |
| ដានីៈ | មួយទៀតលោកអ៊ំ កាលយើងទៅពី១០០១ មានកងពលច្រើនដែរ មានតាំងពីតា០៥, ០៦ ខាងកងពលរបស់លោកអ៊ំ យើងទៅចូល ។ យើងនិយាយឲ្យស្រួលស្តាប់ដូចថាអំណាច ក្រៅពីតាម៉ុក គាត់គ្រប់គ្រងធំ បន្ទាប់ៗពីតាម៉ុក ដែលមានអំណាចបន្តៗមកយ៉ាងម៉េចដែលកាលហ្នឹង? |
| ជាតិៈ | ខ្ញុំចង់ឲ្យក្នុយឯងសួរអាហ្នឹង ។ កាលនោះពួកខ្ញុំខាង១០០១ដល់ពេលតាសុន សេន គាត់ទៅខាងលើ យើងរៀបចំមានតា០៥, ០៦ គាត់ទទួល ។ ដូច្នេះមានអីៗតាមរយៈតា០៥, ០៦ មកជួបនឹងតា ពួកអស់ខ្ញុំអត់បានជួបទេ ជួបតាមរយៈតា០៥, ០៦ ។ |
| បូលីៈ | គាត់ជានាំពាក្យ ឬនាំសារមកជួបតាម៉ុក នេះ? |
| ជាតិៈ | បាទ! ធ្វើដែនការធំជុំគាត់ និយាយរួមពួកអស់ខ្ញុំ ពួកអនុវត្តន៍ ពួកប្រតិបត្តិ ។ |
| បូលីៈ | បច្ចេកទេស អនុវត្តន៍ការងារ ។ |
| ជាតិៈ | អនុវត្តន៍ការងារ ។ |
| បូលីៈ | តាម៉ុក គាត់ធំជាងគេ ដល់ពេលបន្ទាប់ពីតាម៉ុក មកគឺតា០៥, តា០៦ ។ |
| ជាតិៈ | ០៥, ០៦ ហើយនៅខាងនោះហៅតាង៉ុន ក៏គាត់ដូចថាជំនួសមុខ ។ |
| បូលីៈ | ឃីម ង៉ុន? |
| ជាតិៈ | បាទ! ឃីម ង៉ុន ។ |

ដានី៖ ខាងតាម៉ុក មានតាឃីម ផុន មានពីណាទៀត?

ជាតិ៖ តាតេម, តាញ៉ន ។

ដានី៖ គាត់ឈ្មោះ ឃីម តេម ឬយ៉ាងម៉េច?

ជាតិ៖ គេដាក់ក្រោយថា ឃីម តេម ។ លឺតែ ឃីម គ្រប់គ្នា ។

បូលី៖ ឃីម ផុន, ឃីម តេម ម៉េចត្រកូលដូចគ្នា?

ជាតិ៖ ពិបាកថាណាស់ ត្រកូលអត់ទៀង ។ បើ "ឃីម" វិញ ឃីម ផាន់ណា ផង, ឃីម សាន, ឃីម ពឹម ផង ។

ដានី៖ តែគាត់៣-៤នាក់ហ្នឹងមិនមែនបងប្អូនគាត់ទេ?

ជាតិ៖ មិនមែនទេ តែត្រកូល ។

ដានី៖ តាម៉ុក គាត់ខ្ពស់ជាងគេ ហើយមានឋានានុក្រមបន្ទាប់មក មានតាផុន, តាតេម, តា០៥, ០៦ ហើយនិងតាញ៉ន បន្ទាប់ពីហ្នឹងមកមានប៉ុណ្ណឹង ។ មានការងារខាងក្រោម?

ជាតិ៖ មានផ្នែកៗវាទៅ ផ្នែកនោះគេធ្វើតាមផ្នែកនោះទៅ ។

បូលី៖ ក្រោយពេលចរចារសន្តិភាព៩១ រហូតដល់បោះឆ្នោត៩៣ យើងនៅតែបន្តធ្វើសកម្មភាពខាងក្នុងអឺចឹងទៀត ពេលហ្នឹង?

ជាតិ៖ និយាយដល់កន្លែងហ្នឹងពិបាកនិយាយទៀតហើយ ។ បងប្អូនទាំងអស់គ្នា ទាំងមេបញ្ជាការ ទាំងពលទាហាន ចង់បានណាស់៩៣ តែគេអត់ឲ្យចូល ។ ខ្ញុំនិយាយកន្លែងហ្នឹងនិយាយអត់កើតទេ និយាយទៅវាបញ្ច្រាសគ្នា តែការពិតត្រូវតែនិយាយ គេអត់ឲ្យចូល ។

បូលី៖ ខ្ញុំសាកសួរខាងអន្លង់វែងអឺចឹងដែរ ពេលដែលចរចារសន្តិភាពបោះឆ្នោត អ្នកខាងក្រោមចង់ចូលណាស់ តែខាងលើពហិការមិនចូលរួមបោះឆ្នោត ។

ជាតិ៖ មិនពហិការទេវ៉ៃគ្នាបែកក្បាល ក្មួយក៏មានឯកសារមើលដែរ ។

ដានី៖ អ៊ីចង់មានប្រសាសន៍ទាក់ទងរឿង តាខៀវ សំផន ។

ជាតិ៖ បាទ! វ៉ៃបែកក្បាល ក្មួយដឹងហើយក្មួយអ្នកតាមដាន ។ គេអត់ឲ្យចូល ។

បូលី៖ ដោយសារមូលហេតុហ្នឹងបានជាធ្វើពហិការ ព្រោះបែកក្បាលហើយ ។

ជាតិ៖ មិនមែនត្រឹមបែកក្បាលវាមានន័យច្រើន វាដូចថាមាន់ជល់គ្នាអឺចឹងគឺចាប់អាមួយ ឲ្យអាមួយវ៉ៃតាមដំណើរទៅ ក្មួយនៅក្មេងៗខ្ញុំថាតែការពិតនៅតែដឹងប្រវត្តិសាស្ត្រ ។

ដានី៖ អ៊ីចង់មានប្រសាសន៍ថាដល់ពេលគេធ្វើរូបភាពអឺចឹងឲ្យយើងឃើញ ក្នុងបំណងម្ខាងទៀតគេគិតថាមិនចង់ឲ្យយើងចូលរួមជាមួយគេ អឺចឹងគេធ្វើសកម្មភាពអឺចឹងឲ្យហើយ ។

ជាតិ៖ ធ្វើអឺចឹងឲ្យហើយ ដើម្បីថាបើចូលរួមទៅបោះឆ្នោតទៅខ្វាចល់ ។

ដានី: គេធ្វើអីចឹងដើម្បីឲ្យខាងគេមានប្រៀបជាង?

ជាតិ: វាអត់ចូលទេ វាអាក្រក់អីចឹង បានវាអត់ចូល វាអាក្រក់អីចឹងហើយបានវាអត់ចូល ។

បូលី: ខុសទៀត?

ជាតិ: អីចឹងបានថា និយាយដល់កន្លែងហ្នឹងបេះតែទៅ តែខ្ញុំនិយាយការពិត តែខ្ញុំជឿថាមិនមែនដឹងតែខ្ញុំទេ គេដឹងច្រើនគ្នា ដូចខ្ញុំឧទាហរណ៍អីចឹងមាន់ជល់គ្នា តាមដំណើរឈ្នះចាញ់ៗ អាមួយចាប់កន្ទុយ អាមួយកាប់មួយចាក់ទៅ វាអីចឹងឯង ។

ដានី: ការដែលធ្វើពហិការមិនចូលហ្នឹង លោកអ៊ំដឹងថាមុននឹងធ្វើពហិការប្រជុំសិន ប្រជុំគ្នាឯងថាត្រូវសំរេចគួរចូល មិនគួរចូល កាលហ្នឹងអ៊ំដឹងរឿងហ្នឹងគេប្រជុំអីយ៉ាំងម៉េច មុនឈានដល់?

ជាតិ: ខ្ញុំអត់បានប្រជុំទេ គ្រាន់តែដឹងរឿង ដឹងរឿងអី? ខ្ញុំយកឥវ៉ាន់ប្រពន្ធ-កូនរៀបចំនៅកំពង់ចាម ។ ទៅនៅនោះអស់ដើម្បីរៀបចំធ្វើខប ត្រៀមអីចឹងនៅកំពង់ចាម ។

ដានី: កាលហ្នឹងអ៊ំមានតួនាទីអីនៅខាងនេះដែរ បានជាបោះឆ្នោតហើយ អ៊ំថាចូលទៅហើយឈរឈ្មោះជាតំណាងនៅកំពង់ចាម?

ជាតិ: ខ្ញុំមានគំនិតអីចឹង តែកាលហ្នឹងនៅក្មេងអត់ឈឺអីចឹងទេ ឥឡូវអត់ទេ លោកអើយអត់ទេ តែពីមុនអីចឹងឯង ។ រហូតដល់បេះទៀតនិយាយឲ្យអស់ រហូតដល់បងប្អូនខ្ញុំធ្លាប់កសាងថាយើងបោះឆ្នោតឲ្យហ៊្វុនស៊ីប៉ិច បើហ៊្វុនស៊ីប៉ិចឈ្នះទៅហ៊្វុនស៊ីប៉ិចនៅខាងក្នុងយើងអាចថ្ងៃក្រោយរួបរួមគ្នាបាន ហ្នឹងខ្ញុំនិយាយឲ្យអស់ តែឥឡូវខ្ញុំធ្វើបក្សប្រជាជនហើយ ។

ដានី: នេះជាប្រវត្តិសាស្ត្រ ប្រវត្តិពីមុនមក ។

ជាតិ: ប្រាប់ទាំងអស់គ្នា ប្រាប់គ្រប់គ្នាអ្នកណានៅស្រុកណា ខេត្តណា ឲ្យបោះឆ្នោតឲ្យហ៊្វុនស៊ីប៉ិច បើអ្នកណាបន្ទំខ្លួនមានកាត ប្រាប់ឲ្យបោះឆ្នោតឲ្យហ៊្វុនស៊ីប៉ិច ខ្ញុំហើយហ៊្វុនស៊ីប៉ិច តែហ៊្វុនស៊ីប៉ិច បានស្អីរៀបចំ ។

បូលី: ភ្លេចខាងនេះ?

ជាតិ: អត់ភ្លេចទេ យកហ៊្វុនស៊ីប៉ិចមកវ៉ៃ ដល់ចុងបំផុតវ៉ៃជាមួយពីណា វ៉ៃជាមួយ ខាន់ សារឿន វ៉ៃជាមួយ ញ៉ឹក ប៊ុនឆៃ ។ ចុះបើគេប្រើមកហើយ យើងនៅក្រោមគេដែរ អីចឹងវ៉ៃតែម្ដង ។ ខ្ញុំនិយាយការពិតណាក្លួយ ថតទុកចាំទៅ ។ វ៉ៃគ្នាមានអី អីចឹងអ្នកណាធ្វើហ៊្វុនស៊ីប៉ិចឯងសួរតែអញទៅ នៅបក្សប្រជាជនល្អជាង ខ្ពិលគេវ៉ៃត្រឡប់ត្រឡិននៅខាងឈ្នះ ។ ខ្មែរយើងខ្ញុំថាបើកាន់អំណាចបានរឹងប៊ឹងហើយ ខ្មែរមិនដែលស្អប់ខ្មែរទេ ខ្មែរច្បាស់ជារួបរួមគ្នា ខ្ញុំនៅមានជំនឿអីចឹង នៅមានកូនចិត្ត ហើយមានសម្ដេចតេជោ ។

បូលី៖ ជាក់ស្តែងឃើញថាអ៊ីចឹងមែន ឬយ៉ាងម៉េច?

ជាតិ៖ ឃើញថាអ៊ីចឹង ជាក់ស្តែងឃើញអ៊ីចឹង ឃើញថាធ្វើអីៗ យើងរើបំរះពីឃ្លួន ជឿថាខ្មែរមិនចង់នៅធ្វើអី ពីមុនពីងពាក់គេដោយសារអត់ ឥឡូវបានប៉ុណ្ណេះហើយ យើងឱបជាមួយគាត់ ប្រវត្តិសាស្ត្រហ្នឹងលុបទៅ ឱបគោងគ្នាធ្វើទៅ ដូចចប់ត្រឹមហ្នឹង អស់ប៉ុណ្ណឹង ។

ដានី៖ អ៊ុំខ្ញុំមានរឿងមួយសំខាន់មែនទែនដែលខ្ញុំសួរមិនទាន់ដល់ ឈានទៅដល់បែកបាក់រវាងខាងក្រុមខ្មែរក្រហម ។ ដើមហេតុនៃការមានជម្លោះគ្នារវាងក្រុមតាម៉ុក ហើយនិងក្រុមតាប៉ុលពត ឬក្រុមតា០៥, ០៦ អ៊ំមានដឹងថារឿងហ្នឹងយ៉ាងម៉េចបានមានការបែកបាក់គ្នាអ៊ីចឹង?

បូលី៖ រហូតដល់វ៉ៃគ្នាឯង ។

ដានី៖ វ៉ៃគ្នាឯង ហើយលោកអ៊ំពេលមានការខាងតាម៉ុកចាប់អ៊ំម្នាក់ដែលនៅខាងហ្នឹង?

ជាតិ៖ ខ្ញុំតែនិយាយទៅចេះតែឃើញ រឿងដែលបែកបាក់ បើនិយាយពីមហាជនភាគច្រើនអត់ចង់មានការបែកបាក់ទេ រហូតដល់ខ្ញុំខំដាក់ឈ្មោះថាអ៊ីចឹងទៀតខ្លាចបែកបាក់ នៅតែជួបបែកបាក់ តែបែកបាក់ហ្នឹងខ្ញុំឃើញមូលហេតុ តែខ្ញុំនិយាយដូចអាក្រក់ពេក មូលហេតុចង់បានលាភសក្ការៈ ។ ម្នាក់ៗសុទ្ធតែចង់បានលាភសក្ការៈ មានអ៊ីចឹងព្រោះកំលាំងខ្មែរក្រហមដណ្តើមគ្នា២នាក់ កាលនោះដណ្តើមគ្នា២នាក់ ។ ១ហ៊ុនស៊ីប៉ិចបន្តដណ្តើមយកទៀត ១ទៀតរដ្ឋកម្ពុជាដណ្តើម នេះការខ្ញុំឃើញជាក់ស្តែង ចង់បាន ។

បូលី៖ បានន័យថាហ៊ុនស៊ីប៉ិច និងគណបក្សប្រជាជនដណ្តើមយកខ្មែរក្រហម?

ជាតិ៖ បាទ! ដណ្តើមយកខ្មែរក្រហម ។

បូលី៖ ដើម្បីពង្រឹងកំលាំងរៀងៗខ្លួន?

ជាតិ៖ បាទ! ដើម្បីយកទៅអែបរៀងៗខ្លួន ។

បូលី៖ អាហ្នឹងឯងដែលធ្វើឲ្យខាងក្នុងនេះបែកបាក់គ្នា ។

ជាតិ៖ បាទ!

បូលី៖ ព្រោះមួយបែកទៅរកហ៊ុនស៊ីប៉ិច មួយចង់ទៅចូលគណបក្សប្រជាជន ។

ជាតិ៖ រហូតទៅដល់មានការមកយកកំលាំង រឿងព្រឹត្តិការណ៍យន្តហោះ ហ្នឹងហ៊ុនស៊ីប៉ិចទេមកយកចុះកាលហ្នឹងចៅហ្វាយខេត្តសៀមរាបយើងលោក ហែង ប៊ុនហេង និយាយទៅដូចក្នុងរឿងមូលហេតុមកពីដណ្តើម ។

បូលី៖ អ៊ំអាចញែកបានទេ? ខាងណាចង់ចូលទៅខាងគណបក្សប្រជាជន ខាងណាចង់ចូលទៅហ៊ុនស៊ីប៉ិច? កងពលណាខ្លះ?

ជាតិៈ ខ្ញុំមើលទៅ ខ្ញុំអត់ចង់ហ៊ានថាគេទេ ។ តែមើលពីការទាក់ទង នៅខាងតាផុន ថាហ្នឹងគាត់ទាក់ទងហ៊្វុនស៊ីប៉ិច ។

បូលីៈ ឃីម ផុន?

ជាតិៈ បាទ! គាត់ទាក់ទងហ៊្វុនស៊ីប៉ិច ទាក់ទងគ្នាតាមយន្តហោះ ហ្នឹងខ្ញុំឃើញជាក់ស្តែង អត់ចេះតែថាទេ ។

បូលីៈ បានន័យថាខាងតាម៉ុក ចង់ផាកទៅរកហ៊្វុនស៊ីប៉ិច?

ជាតិៈ បាទ!

បូលីៈ ខាងតា០៥, ០៦ ផាកទៅណាពេលហ្នឹង?

ជាតិៈ ខ្ញុំអត់ទាន់យល់ចិត្តគាត់ទេ គាត់យល់ថា ខ្ញុំលឺសំដីគាត់ "ថាមិត្តឯងគិតមើលយើងកុំចោលតា ហើយកុំចោលអ៊ំ ។

បូលីៈ អ៊ំ ពីណា?

ជាតិៈ អ៊ំប៉ុល ពត ។

បូលីៈ តា ពីណា?

ជាតិៈ តាម៉ុក យើងដែលតស៊ូមកបានប៉ុណ្ណេះដោយសារមានតា មានអ៊ំ ។ តាគាត់អត់ចេះអីមែនតែយើងអ្នកស្រែ អ្នកចំការទាំងអស់គ្នា រួមរស់ជាមួយគ្នា ។ ហើយគាត់ថាគាត់បានធំបានធាត់ បានចេះដឹងប៉ុណ្ណឹងដោយសារតា ។ ដូច្នេះគាត់ថាសុខចិត្តឲ្យទៅស្លាប់ជាមួយដៃតាពិសេសតា០៥ ។

បូលីៈ មើលទៅគាត់ដូចជាស្រឡាញ់តាម៉ុក ។ បើស្លាប់អីចឹងទៅតា០៥?

ជាតិៈ បាទ!

បូលីៈ ខាងណាដែលចង់ផាកទៅរកគណបក្សប្រជាជន?

ជាតិៈ វាអត់មានខាងណាៗទេ គ្រាន់តែថាអ្នកក្រោមៗទាំងគេ ទាំងខ្ញុំ ពិសេសខ្ញុំថាទាល់តែរត់ទៅរកបក្សប្រជាជន ។

ដានីៈ អ៊ំមានប្រសាសន៍អីចឹងដូចមានបន្ទប់មួយ រឿងរ៉ាវទាំងអស់ហ្នឹងវាកើតចេញមកពីតាឃីមផុន មិនអីចឹងអ៊ំ?

ជាតិៈ ទេ ។

ដានីៈ អាចថាគាត់ទៅទាក់ទងខាងហ៊្វុនស៊ីប៉ិច តែខាងលើ ខាងអ៊ំនេះមិនទាន់ចង់ ។

ជាតិៈ អត់ទៅទាក់ទងខាងណាទេ គិតថាចង់រួបរួមគ្នាឲ្យបានចូលត្រីភាគី ។ គេហៅពហុបក្ស គិតចង់ធ្វើអីចឹង ។

បូលី៖ មិនខ្វល់ថាខាងណាជាខាងណាទេ?

ជាតិ៖ អត់ខ្វល់ខាងណាៗទេ នឹកឃើញនៅជាមួយជាតិ៖ នៅជាមួយប្រជាជន ហើយយើងបង្កើតជាបក្សបើសិនជាមានលទ្ធភាព។ ឥឡូវអត់ទេក្មួយគ្រាន់តែនិយាយកាលនោះ។

បូលី៖ តែមើលទៅតាងុន គាត់ហាក់ដូចជាចង់ចូលទៅខាងហ៊ុនស៊ីប៊ិច?

ជាតិ៖ ខ្ញុំនិយាយកាន់តែជ្រៅទៀត បានជាខ្ញុំថាអីចឹង កាលខ្ញុំចេញមកវៃគ្នាជាមួយ កាលវៃគ្នាខ្ញុំនៅខាងតា០៥ លោកក្មួយយន្តហោះដេញព័ទ្ធចាប់។

បូលី៖ យន្តហោះខាងណា?

ជាតិ៖ មិនដឹងខាងណា បែបមកពីភ្នំពេញ យើងអត់យល់ដែរ។ រហូតដល់ពេលខ្ញុំផ្ដាច់ខ្លួនមកហើយ បងប្អូននេះអត់ទាន់ផ្ដាច់ខ្លួន ពួកនេះចង់ធ្វើឲ្យកងទ័ពមានប្រាក់ខែចូលខាងអាមេរិកគេជួយទាហាន។

ដានី៖ ស៊ីអេសអេស?

ជាតិ៖ ហ្នឹងហើយ ចង់ចូលអាហ្នឹងពួកហ្នឹង ចង់ចូលអាហ្នឹងទៀត និយាយពួកហ្នឹងយើងអត់យល់។

បូលី៖ ឈឹម យ៉ាំសិទ្ធិ?

ជាតិ៖ បាទ!

បូលី៖ មេធំនៅអាមេរិក?

ជាតិ៖ បាទ! ដែលខ្ញុំផ្ដាច់ខ្លួនមកហើយ អីចឹងបានខ្ញុំថាខ្លាចស្លាប់ ខំយកទាំងអស់ឥឡូវមកនៅជាមួយសម្ដេចតេជោ កាលហ្នឹងគេហៅសម្ដេចហ៊ុន សែន។ អានេះការពិតបងប្អូនអត់ដឹងតែខ្ញុំឃើញ។

ដានី៖ កាលហ្នឹងបែកបាក់ហើយ តាម៉ុក ចាប់តា០៥, ០៦ ហើយនិងមួយចំនួនទៀតទៅសម្លាប់ ហើយកាលហ្នឹងអ៊ំ ហើយប៉ុន្មាននាក់ទៀតគាត់ចាប់យកទៅឃុំ?

ជាតិ៖ នៅកន្លែងអន្លង់វែង។

ដានី៖ ក្នុងមន្ទីរ?

ជាតិ៖ មន្ទីរ១៩ ឲ្យលាងខួរក្បាល។

ដានី៖ យ៉ាំងម៉េចដែលអ៊ំអាចមានប្រសាសន៍កន្លែងហ្នឹងបន្តិច?

ជាតិ៖ ខ្ញុំនឹកទៅចង់តែសើច បាននឹកចង់សើច និយាយទៅដូចយើងនិយាយរដ្ឋកម្ពុជាឆ្នាំ៧៩អីចឹងគេនិយាយអីចឹងឯង អាពត កាប់សម្លាប់ អាពត ឃាតករ មានតែខ្ញុំទេដែលមិនប្រឡាក់ឈាម និយាយអីចឹងឯង។

ដានី៖ អ្នកណាអ្នកនិយាយអីចឹង?

ជាតិៈ តាម៉ុក ។

ជានីៈ មកនិយាយប្រាប់ខាងអ៊ំ?

ជាតិៈ ប្រាប់បងប្អូនទាំងអស់គ្នា ហៅប្រជុំ ហៅសាលា ហើយគេរកមុខអ្នកណាដុតអីៗ ខ្ញុំនៅខាង នោះ ខ្ញុំនៅខាងចាញ់របូត ។

ជានីៈ កាលហ្នឹងពីណាខ្លះដែលជាប់ជាមួយអ៊ំនៅមន្ទីរ១៩?

ជាតិៈ ជាប់ជាមួយខ្ញុំ, អ៊ំកែវ ។

ជានីៈ ជា កែវ?

ជាតិៈ បាទ! លោកវ៉ាន់ កុសល, វ៉ែ ពិន ឥឡូវធ្វើស៊ុបនៅព្រះវិហារ ។

ជានីៈ ៤នាក់ហ្នឹងទេ?

បូលីៈ សុទ្ធតែមេធំៗជាប់?

ជាតិៈ អត់ធំប៉ុន្មានទេ គ្រាន់តែថាយើងលំដាប់ ។

បូលីៈ បន្ទាប់ពីតា០៥?

ជាតិៈ បន្ទាប់ពីតាៗហ្នឹងមក ។

ជានីៈ ម៉េចបានអ៊ំអាចរួចចេញពីមន្ទីរហ្នឹង យើងអាចទៅនេះបាន?

ជាតិៈ រួចចេញខ្ញុំរត់ បើនិយាយរឿងរត់វេទនាណាស់ កូនខ្ញុំសុទ្ធតែរត់ ។

បូលីៈ កូនស្រីនេះ?

ជាតិៈ បាទ!

ជានីៈ កាលហ្នឹងតាម៉ុក គាត់យកទៅទាំងគ្រួសារតែម្តងនៅមន្ទីរ?

ជាតិៈ មុនដំបូងយកតែខ្ញុំទេ ដល់ហើយមកទៀតចង់យកទាំងគ្រួសារ ដល់លឺយកទាំងគ្រួសារខ្ញុំអត់ មានទាក់ទងអីតិចសោះ អត់រលីងតែម្តង រត់យករួចខ្លួនតែម្តង រត់ខ្លាចងាប់ ។

ជានីៈ អ៊ំរត់មកហ្នឹងគ្រួសារអត់ទាន់ទៅមន្ទីរ១៩ទេ?

ជាតិៈៈ អត់ទាន់ទៅទេ ។

ជានីៈ និយាយទៅអ៊ំទៅជាប់នៅហ្នឹងរយៈពេលប៉ុន្មានទៅ?

ជាតិៈ ដូចជា១ឆ្នាំ ។

ជានីៈ ១ឆ្នាំ? យូរដែលអីចឹងនៅហ្នឹង?

ជាតិៈ មួយរដូវ ៦ខែ ។ ទៅហ្នឹងចេះទេគេឲ្យយើងរៀន អង្គុយស្តាប់គេ យើងធ្លាប់តែធ្វើមេគេ អង្គុយស្តាប់គេ ។

ជានីៈ អ្នកមកបង្រៀនហ្នឹងពីណាគេ?

ជាតិៈ		ក្មាងង ។

បូលីៈ		ពីណាគេ?

ជាតិៈ		ឥឡូវគេស្លាប់ហើយ?

បូលីៈ		តាង៉ុន?

ជាតិៈ		មិនមែនតាង៉ុនទេ អ្នកធំហើយគេអត់បង្រៀន គេបង្រៀនអ្នកល្មម ។ តាញ៉ែន ។

ដានីៈ		អ៊ីចាំថ្ងៃខែដែលអ៊ីលួចរត់? គ្នាប៉ុន្មាននាក់? ហើយទៅចូលកន្លែងណា? ហើយម៉េចទៀតពេលហ្នឹងចាប់ពីចលនាផ្តាច់ខ្លួន?

ជាតិៈ		អត់ចាំថ្ងៃទេ ខែ១២ ឆ្នាំ៩៨ ខ្ញុំទៅតាំងពី៩៨ ។

ដានីៈ		ដល់ពេលអ៊ីរត់ពីមន្ទីរ?

ជាតិៈ		តាំងពីជើងភ្នំ អូរស្វាយ ។

ដានីៈ		មន្ទីរ១៩នៅណាទៅ?

ជាតិៈ		មន្ទីរ១៩នៅអន្លង់វែង តែផ្ទះខ្ញុំនៅនេះ ។

អ្នកជិតខាងៈកន្លែងគេដាក់ធនាគារធំ ។

ដានីៈ		ធនាគារអេស៊ីលីដាហ្នឹង?

ជាតិៈ		អេស៊ីលីដា ។

ដានីៈ		អ៊ីរត់ពីហ្នឹងមកតាមជំនៀរតាមព្រំដែន?

ជាតិៈ		រត់ឆ្ងាយហ្នឹងធ្លាក់ទៅស្រុកគូលេន ។

ដានីៈ		ប៉ុន្មាននាក់រត់ទៅហ្នឹង?

ជាតិៈ		ខ្ញុំរត់ទៅហ្នឹង៤-៥នាក់ តែខ្ញុំរត់ដាច់កូន ដាច់ប្រពន្ធ ខ្ញុំរត់ទៅតែឯង កូន-ប្រពន្ធរត់ផ្សេង

ដានីៈ		អ្នកនៅក្នុងដែលជាប់ជាមួយអ៊ីរត់ទៅទាំងអស់គ្នា ឬអត់ទេ?

ជាតិៈ		រត់ទៅទាំងអស់គ្នា ។

ដានីៈ		ដល់ពេលអ៊ីរត់ទៅ ទៅចូលជាមួយខាងរដ្ឋាភិបាលនៅកន្លែងណា? ហើយពេលហ្នឹងយ៉ាងម៉េចដែរ?

ជាតិៈ		ដល់ពេលរត់បាត់ពីនេះ ប៉ុស្តិ៍វិទ្យុគេផ្សាយ វិទ្យុខ្មែរក្រហមថាខ្ញុំស្អីៗ គេផ្សាយគេដឹងគេលឺហើយគេតេអូទៀត ទាក់ទងគេចាំត្រង ។ ខ្ញុំដូចសំណាងមានដែលបានបងអភិបាលខេត្តកាលហ្នឹងបងឃួយ ស៊ីនហួរ ។

ដានីៈ		អភិបាលខេត្តកំពតរាល់ថ្ងៃ?

ជាតិៈ កំពតរាល់ថ្ងៃ បានគាត់ហ្នឹងហើយគិតគូរ រៀបចំ គាត់ស្រឡាញ់រាប់រកដូចបងប្អូន ថាអរ អើយអរ ។

ដានីៈ អ៊ំរត់ទៅប៉ុន្មានថ្ងៃបានទៅដល់ព្រះវិហារ?

ជាតិៈ ៨ថ្ងៃ ។

ដានីៈ ៨ថ្ងៃបានទៅដល់ទីរួមខេត្តព្រះវិហារ?

ជាតិៈ បាទ! ៨ថ្ងៃ ។ លបៗផង ។

ដានីៈ ដល់ពេលទៅដល់ខេត្តព្រះវិហារ ជួបជាមួយលោកអភិបាលខេត្ត ឃួយ ស៊ីងហួរ ហើយ យ៉ាងម៉េចទៀតសកម្មភាពយ៉ាងម៉េច ដើម្បីចលនាផ្តាច់ខ្លួននៅខាងត្រពាំងប្រាសាទយើងទាំងមូល?

ជាតិៈ កាលនោះខ្ញុំទៅគ្រាន់បានយប់ ស្អែកឡើងខ្ញុំទៅភ្នំពេញ ទៅជួបជាមួយបងៗខាងនោះ ឌុំ ហាក់ ។ ពិតប្រាកដ មិនពិតប្រាកដ ។

ដានីៈ ឯកឧត្តមសេនីយ៍ឌុំ ហាក់, មុល រឿង គាត់ស្លាប់ហើយឥឡូវ ។

បូលីៈ ជិះអីទៅអំពីព្រះវិហារទៅភ្នំពេញ?

ជាតិៈ ជិះយន្តហោះ ។

បូលីៈ ទៅជួបគាត់នៅណាវិញ? នៅក្រសួង ឬនៅណា?

ជាតិៈ អត់ទេ នៅកន្លែងស្ងៀមៗទេកាលហ្នឹងយើងអត់ទាន់ស្គាល់អស់ កន្លែងសណ្ឋាគាគេ ។

ដានីៈ មិនមែនទៅជួបនៅទីស្តីការ ក្រសួង ឬអគ្គបញ្ជាការទេ? ទៅកន្លែងផ្សេងទេ?

ជាតិៈ បាទ! កន្លែងផ្សេង ដូចថាយើងសំងាត់ ជួបគ្នាសំងាត់ ។

ដានីៈ ព្រោះ មុល រឿង គាត់ខាងស៊ើបការណ៍សំងាន់, ខាងចារកិច្ច ។ ដល់ពេលជួបគាត់រៀប យុទ្ធសាស្ត្រអីយ៉ាងម៉េច?

ជាតិៈ ជួបគាត់ គាត់រៀបយុទ្ធសាស្ត្រ គាត់និយាយ២ ។ ទី១គាត់អត់ចង់ឲ្យខ្ញុំបែកទេ ឲ្យសំងាត់ ឲ្យទៅធ្វើការក្នុងតំបន់ខ្មែរក្រហមវិញ ដល់ពេលអីចឹង ខ្ញុំថាអត់ទេឯកឧត្តម អត់ទៅរួចទេខ្ញុំ ព្រោះប្រជាជនគេចង់មកខាងរដ្ឋាភិបាលសំបើមណាស់ គេអត់នៅនោះទេ ។ ដល់អីចឹងគាត់ សំរេចចិត្តធ្វើឯកសារបោះខិតបណ្ណតាមយន្តហោះ ខ្ញុំប្រើយន្តហោះម្តង ។

បូលីៈ លែងដើរផ្សព្វផ្សាយហើយ ។

ជាតិៈ បាទ! យន្តហោះគេខាងលើទេ បោះទៅហើយប្រាប់ បន្រ្ទមជួយរំដោះ ដូចហឹកហាក់ដែរ ហើយខ្ញុំទៅណាមកណា ទៅស្ទឹងត្រែង ទៅរតនគិរី សុទ្ធតែជិះយន្តហោះកាលហ្នឹង ។ ព្រោះធ្វើមេមុនដំបូង គេឲ្យជិះយន្តហោះ ។

បូលីៈ	មកបាចខិតបណ្ណនៅត្រពាំងប្រាសាទ អន្លង់វែងយើងហ្នឹង?

ជាតិៈ	បាទ! ក្មេងៗណាក៏គេដឹងដែរ ។

ជានីៈ	គាត់មានជំរើស២ ជំរើសទី១ឲ្យអ៊ំចូលមកវិញ មកធ្វើការជាមួយខ្មែរក្រហម ។ ហើយជំរើសមួយទៀត ធ្វើខិតបណ្ណហ្នឹងឃោសនា បោះត្រាក់ហ្នឹង ដើម្បីនេះ ។ ជំរើសទី១ អ៊ំបដិសេធន៍ថាមិនអាចចូលមកវិញទេ គេដឹងថាយកសម្លាប់ហើយ ។ ដល់អីចឹងខាងគាត់២នាក់ហ្នឹងក៏គាត់ឯកភាពយកជំរើសទី២ ។

ជាតិៈ	បាទ!

ជានីៈ	ជំរើសទី២ហ្នឹងខិតបណ្ណជាគំនិតផ្តួចផ្តើមរបស់អ៊ំធ្វើ អ៊ំសរសេរ ឬខាងរដ្ឋាភិបាល?

ជាតិៈ	រដ្ឋាភិបាល ។

ជានីៈ	ក្នុងអត្ថន័យ ក្នុងខិតបណ្ណហ្នឹងសរសេរថាម៉េចខ្លះ?

ជាតិៈ	ចង់ភ្លេចអស់ដែរ ខិតបណ្ណអំពាវនាវបងប្អូន ភ្ញាក់រំលឹកឡើង តស៊ូមកជាមួយរដ្ឋាភិបាល ហើយមានខ្ញុំប៉ុន្មាននាក់មកហើយ បានសុខសប្បាយអត់អីទេ ។

ជានីៈ	កាលហ្នឹងអ៊ំ?

ជាតិៈ	ជា កែវ ។

បូលីៈ	វ៉ាន់ កុសល?

ជាតិៈ	អត់ទេ វ៉ាន់ កុសល អត់ទៅទេ ។

ជានីៈ	ពីណាទៀត?

ជាតិៈ	សារី សយ ហើយនិងពិន ដែលខ្ញុំថាធ្វើស៊ុបនៅព្រះវិហារ ។

ជានីៈ	អីចឹង៤នាក់?

ជាតិៈ	៤នាក់ ។

ជានីៈ	ទៅភ្នំពេញក៏ទៅ៤នាក់ដែរ?

ជាតិៈ	ទៅ ។

ជានីៈ	ពេលប្រជុំជាមួយគាត់ ប្រជុំ៤នាក់ហ្នឹងដែរ?

ជាតិៈ	បាទ!

ជានីៈ	អីចឹងអ៊ំស្នាក់នៅភ្នំពេញរយៈពេលប៉ុន្មានថ្ងៃដែរ?

ជាតិៈ	ទៅឡើងចង់សហើយកាលហ្នឹងម៉ៅខ្វាំង ។ ខ្ញុំនៅលីឡាយ ។

ជានីៈ	លី ឡាយ ។

ជាតិៈ	នៅប្រហែល១ខែ ។

ដានី: អីចឹងពេលប្រជុំអីហើយ ធ្វើខិតបណ្ណ ប្រហែល១ខែ?

ជាតិ: មែនទែនទៅបំប៉នសុខភាពផង បាក់ស្កម ។

ដានី: ទៅកាលហ្នឹងក្រុមគ្រួសារទៅទាំងអស់?

ជាតិ: អត់ទៅទេ គ្រួសារនៅព្រះវិហារធ្វើផ្ទះ ខ្ញុំមានរបបដីផ្ទះនៅព្រះវិហារ ។

ដានី: ធ្វើអ៊ំទៅព្រះវិហារ កាលហ្នឹងអារម្មណ៍អ៊ំយ៉ាងម៉េច? ភ័យព្រួយ មិនទុកចិត្ត រដ្ឋាភិបាល ឬយ៉ាងម៉េចដែរពេលដែលអ៊ំស្នាក់នៅភ្នំពេញ?

ជាតិ: ចិត្តខ្ញុំថាទុកចិត្ត ខ្ញុំនឹកឃើញថាបើសម្លាប់ខ្ញុំមួយក៏អត់មានន័យ បើខ្ញុំនៅខ្ញុំរួមចំណែកជាមួយរដ្ឋាភិបាលធ្វើអីបានទៀត ។ ខ្ញុំធ្លាប់ពិសោធន៍ ខ្ញុំចិញ្ចឹមឆ្កែ ចិញ្ចឹមពីតូច ឆ្កែខ្ញុំខូចលួចស៊ីត្រីស៊ីសាច់ អាណាទៅក៏វៃដែរ ស្រាប់តែឆ្កែហ្នឹងធំឡើងវាចេះបណ្ដើរសត្វ អាណាមួយក៏រាប់អានឆ្កែ ។ ខ្ញុំនឹកឃើញឆ្កែគេរាប់អាន ចុះខ្ញុំមនុស្ស ខ្ញុំធ្វើខ្ញុំស្មោះ អីចឹងបានមុននិយាយប្រាប់ក្មួយៗថាខ្ញុំស្អីដែលអត់ចំណេញដល់បក្សប្រជាជនខ្ញុំសុំអត់និយាយ វាអីចឹងឯង ខ្ញុំតាំងចិត្តអីចឹង ។

ដានី: កាលអ៊ំស្នាក់នៅលីឡាយទាំង៤នាក់ មានការជូនទៅទស្សនៈកិច្ច ឬទៅកំសាន្តណាណីដែរ?

ជាតិ: ក្រោយមកទៀតបានខ្ញុំហ្នឹងទៅ បានលទ្ធផលដែរ ដូចក្រុមហ៊ុនទាល់តែលក់ដាច់បានគេឲ្យពិន្ទុ ដល់ពេលបានលទ្ធផលទៅខាងស្ទឹងត្រែង បងប្អូនមកទាំងរយ ក៏ដឹកបងប្អូនទាំងអស់គ្នាទៅលេងកំពង់សោម ខ្លះបន្ទោសថាបង យូរហើយបើដឹងថាសប្បាយអីចឹងមិនបបួលខ្ញុំតាំងពីមុន ។

បូលី: ម៉េចបានទៅដឹកស្ទឹងត្រែង រតនគិរីវិញអ៊ំ? គាត់រត់ទៅខាងហ្នឹង?

ជាតិ: ខ្ញុំទៅបំផុសបំផុលខាងហ្នឹង ។

ដានី: ខាងហ្នឹងពីណាគេ?

ជាតិ: ខាងហ្នឹងស្លាប់អស់ខ្លះហើយ នៅបងប្រ៉ូ(ស្លាប់) ។

បូលី: អតីត៨០១?

ជាតិ: បាទ! អតីត៨០១ ។

ដានី: តាធិន?

ជាតិ: ហ្នឹងហើយតាធិន ប្ដីយាយវ៉ាន់ ហ្នឹងមកតាមរយៈខ្ញុំ ។

បូលី: ឌី ធិន ជាប់ពូក្មេកឯកឧត្ដម ឃឹម ដាន់ណា ។

ជាតិ: បាទ!

ដានី៖ ប្រពន្ធគាត់មុនត្រូវជាក្មួយរបស់តាធិន ។ អ៊ីចឹងអ៊ំនៅមួយខែហ្នឹង ក្នុងមួយខែហ្នឹងរដ្ឋាភិបាលអញ្ជើញអ៊ំទៅខាងស៊ីងក្រែងធ្វើការឃោសនា អូសទាញពីខាងស៊ីងក្រែងមក ក្នុងរយៈពេលមួយខែហ្នឹង ឬក្រោយ១ខែហ្នឹងទៀត?

ជាតិ៖ ក្រោយ ខាងលើរៀបចំថាធ្វើម៉េច បាទខ្ញុំ ។

ដានី៖ ក្នុងរយៈពេលមួយខែហ្នឹងពេលអ៊ំត្រឡប់មកវិញមានទិតបណ្ណមកជាមួយអ៊ំដែរ?

ជាតិ៖ អត់ទេ ធ្វើតាំងពីខ្ញុំនៅភ្នំពេញ ។

ដានី៖ កប៉ាល់ហោះដែលចុះមកបាចហ្នឹងមិនមែនអ៊ំមកជាមួយយន្តហោះហ្នឹងទេ?

ជាតិ៖ អត់ទេ ខ្ញុំនៅភ្នំពេញ ។

បូលី៖ ឲ្យគេមកបាចទេ ។

ដានី៖ ខាងរដ្ឋាភិបាលទេគេបើកយន្តហោះមកបាចហ្នឹង?

ជាតិ៖ បាទ! អ៊ីចឹងតា៎ ។

បូលី៖ ប៉ុន្មានពាន់សន្លឹកអ៊ំមានដឹងទេ?

ជាតិ៖ ទេ មិនដឹងប៉ុន្មានពាន់ទេ បាចតាំងពីហ្នឹងទៅអន្លង់វែង ។

បូលី៖ មានចុះហត្ថលេខារបស់អ៊ំនៅលើទិតបណ្ណហ្នឹងទេ?

ជាតិ៖ អត់ទេ មានរូបថត ។

ដានី៖ គេដាក់រូបថតអ៊ំក្នុងទិតបណ្ណហ្នឹង ។

ជាតិ៖ បាទ!

ដានី៖ ហើយដល់ពេលអ៊ំមានលឺព័ត៌មានថានៅក្នុងទិតបណ្ណ ពីខាងបងប្អូន ពីអ្នកដែលធ្លាប់នៅជាមួយអ៊ំ គេនិយាយប្រាប់អ៊ំ ឬយ៉ាងម៉េចអ៊ីវិញដែលអត់?

ជាតិ៖៖ ខ្ញុំទាក់ទងជាប់ដែរ ខ្ញុំទាក់ទងតាមទូរលេខ តាមគេអូ ។

បូលី៖ ជាមួយពីណាអ្នកខាងក្នុងនេះ?

ជាតិ៖ នៅក្នុងនេះជាមួយ ឆាំ លោកអ៊ីឆាំ ទេស្លាប់បាត់ហើយ ។ សុំ អ៊ីហ្នឹង ។

ដានី៖ ជាមួយពីណា? ជាមួយឆាំ ជាមួយពីណាមួយទៀត?

ជាតិ៖ ជាមួយ សុំ ។ ហើយទាក់ទងជាមួយស្អីគេនៅនេះ កូនប្រសារតាស័ន ។

អ្នកជិតខាង៖ នុន ។

ជាតិ៖ នុន ឥឡូវគេផ្កាយ២-៣នៅជាមួយតាគន់ គីម ចុះគេក្មេង ។

ដានី៖ ពេល១ខែដែលអ៊ំត្រឡប់មកវិញ អ៊ំត្រឡប់មកដល់ត្រពាំងប្រាសាទវិញ ឬនៅត្រឹមព្រះវិហារ?

ជាតិៈ អត់ទេ ខ្ញុំនៅស៊ីនត្រែង នៅទល់តែកូន-ប្រពន្ធចង់ភ័យ នៅបង្កប់ខ្លួន ។

បូលីៈ ធ្វើម៉េចដើម្បីបានមកចលនាខាងនេះឲ្យផ្តាច់ខ្លួនទៅបាន? បើអ៊ំនៅឆ្ងាយ ។

ជាតិៈ ចុះមានគេ មិនមែនមានតែយើងណា ។ ដល់ហើយពេលវៃគ្នាបានខ្ញុំមកវៃហើយ មក២នាក់ជាមួយអ៊ំកែវ លើកទ័ពមកវៃផ្តាច់យកអន្លង់វែង ខ្ញុំនៅជាប់កងពលលេខ១, លេខ៣ តាស្រី ឌឹក ខ្ញុំនៅកាន់ ។ ហើយលោកយឹម ផាន់ណា នៅខាងតាអ៊ូច សុភាព ខាងនេះ ។

ដានីៈ ខាងអូរបាយតាប់?

ជាតិៈ បាទ!

ដានីៈ អូរបាយតាប់ ខាងយុទ្ធភូមិភាគ៤ ។

ជាតិៈ បាទ!

ដានីៈ ហើយខាងអ៊ំខាងអីគេ?

បូលីៈ ស្រី ឌឹក ។

ដានីៈ ស្រី ឌឹក តែគេហៅទិសខាងអីវិញ? ខាងនេះយុទ្ធភូមិភាគ៤ ។

ជាតិៈ នេះ៤ទាំងអស់គ្នា ។

ដានីៈ ភូមិភាគ៤ទាំងអស់គ្នា?

ជាតិៈ យុទ្ធភូមិភាគ៤ទាំងអស់គ្នា គ្រាន់តែមានអគ្គ កាលនោះខ្ញុំនៅជាប់ជាមួយបងមាស សុភា ។

ដានីៈ ខែប៉ុន្មានដែលអ៊ំដឹកនាំទ័ពមកវៃវិញ? យើងទៅខែ១២ ឆ្នាំ៩៨ ។

ជាតិៈ មិនបានចាំទេក្មួយ គ្រាន់តែខែនេះខែគេច្រូតរួច ។

បូលីៈ ខែមករា ឆ្នាំ៩៩?

ជាតិៈ មករា-កុម្ភៈតាមមើល ។

ដានីៈ ឥឡូវនេះខែច្រូតដែរ?

ជាតិៈ ច្រូតហើយ យើងមិនទាន់មករាទេ ។

បូលីៈ ធ្នូ ៩៨?

ជាតិៈៈ កាលហ្នឹងគេច្រូតស្រូវហើយដាក់ជង្រុក ។

អ្នកជិតខាងៈ ច្រូតហើយ ខែ១ ខ្ញុំទៅចាំបងនៅទំនប់ខ្មោចបងសូរិយាធ្វើនោះ ។

ជាតិៈៈ ព្រោះឥឡូវយើងទើបតែបោកបែន កាលនោះយើងដាក់ស្រូវ ដាក់ជង្រុកហើយ ។

បូលីៈ អ៊ីចឹងខែ១ ៩៩?

ដានីៈ មកវៃរយៈពេលប៉ុន្មានដែលយើងវៃដាច់?

ជាតិៈ	អ៊ឹ! ២-៣ខែដែល គ្រាន់តែស្លាប់មនុស្សអស់៦០នាក់ពួកខ្ញុំ វ៉ៃហើយ កុំថាខ្មែរក្រហម ពូកែវ៉ៃដែរ វ៉ៃស្លាប់៦០នាក់ ។

ដានីៈ	ខាងអ៊ីខ្មែរក្រហមដែរ?

ជាតិៈ	ខ្ញុំទៅខាងរដ្ឋាភិបាល ។

ដានីៈ	ដឹកនាំកំលាំងខាងរដ្ឋាភិបាលមកវ៉ៃ?

ជាតិៈ	បាទ! ទាំងពួកខ្ញុំ ទាំងពួកទាហាន ទាំងអស់៦០នាក់ខ្ញុំចាំ ។

ដានីៈ	ខាងតាម៉ុក ខ្លាំងដែរ?

ជាតិៈ	ខ្លាំងអីចឹង ទាល់តែយួនចាញ់ ខ្ញុំឡើងខ្លាច ដាក់មីនទៅភ័យ ធ្លាប់នៅជាមួយអ្នកមីនហើយ ខ្លាចអ្នកមីនហ្នឹងទៀត ។ ទាហានបានពួកខ្ញុំមក ដែលហ៊ានមក និយាយមិនអួត គ្នាអត់ដែលស្គាល់ភូមិសាស្ត្រសោះ ។

ដានីៈ	ដល់ពេលបានជ័យជំនះទាំងស្រុងខែប៉ុន្មានទៅ? ខែប៉ុន្មានបានជ័យជំនះទាំងស្រុងហើយ យើងចាប់ផ្តើមរៀបចំ?

ជាតិៈ	ខ្ញុំអត់ចាំ ដល់ពេលវ៉ៃបែកអស់ហើយ បងប្អូនប្រមូលមួយកំណាត់ នៅមួយកំណាត់ បានភាគច្រើន នៅភាគតិចទេ ។

ដានីៈ	មួយកំណាត់នៅខាងភូណាយ?

ជាតិៈ	បាទ! នៅភូណាយ ទាល់តែខំប្រឹង ពួកខ្ញុំទៅឆារឆៅអីទៀត ពួកទ័ពឆារឆៅទៀត ។ កាលនៅភូណាយហើយគេថាចង់ធ្វើស្អី ។

ដានីៈ	ស៊ីអេសអេសហ្នឹង?

ជាតិៈ	ហ្នឹងហើយ ហើយពូកុសល គេនៅខាងហ្នឹង ។

ដានីៈ	នៅខាងភូណាយ?

ជាតិៈ	អីចឹងគាត់ថ្នាក់ធំ ហើយមកធ្វើក្រោមគេ មកនៅក្រោយគេ អីចឹងឯង ។ ឥឡូវគាត់អាក្រែតហើយ ខ្ញុំក៏អាក្រែតដែរ ។

បូលីៈ	អ្នកដែលដឹកនាំទ័ពរដ្ឋាភិបាលមកវ៉ៃហ្នឹងអ៊ំ ឬពីណា?

ជាតិៈ	ទេ មានគេមានឯង ។

បូលីៈ	ខាងរដ្ឋាភិបាលមានមេដឹកនាំមួយទៀត បញ្ញាការ?

ជាតិៈ	មាន បងស្រី ឌឹក ។

បូលីៈ	គាត់មកជាប់តែម្តង?

ដានីៈ	តែឯកឧត្តម ស្រី ឌឹក គាត់មកជាប់?

ជាតិៈ	គាត់មកជាប់ ហើយនិងឯកឧត្តម មាស សុភា គាត់តាមជាប់, ជា ស្រន ។

បូលីៈ	សមរភូមិតែម្តង?

ជាតិៈ	សមរភូមិអី ។

បូលីៈ	គាត់បញ្ជាពីក្រោយទេ?

ជាតិៈ	គាត់បញ្ជាពីក្រោយ ។

បូលីៈ	អ្នកដែលចុះជាប់?

ដានីៈ	ដែលកៀកស្នាជាមួយអ៊ំ, ជាមួយ ជា កែវ មកជាមួយហ្នឹង ពីណា?

ជាតិៈ	ស៊ីដែលខ្មៅ និយាយរួមកនពល អនុហ្នឹង ។

បូលីៈ	ចុះបញ្ជាការរួមដែលសំរាប់វាយកអន្លង់វែងតែម្តងពីណាគេ?

ជាតិៈ	ខ្ញុំអត់ដឹងទេ តែគ្មានពីណាជាង តាមាស សុភា ។

ដានីៈ	មាស សុភា គាត់មេបញ្ជាការកងទ័ពជើងគោក ។

ជាតិៈ	កងទ័ពជើងគោក ។ តាជា ម៉ន ។

ដានីៈ	ជា ម៉ន យុទ្ធភូមិភាគ៤?

ជាតិៈ	៤ ។

ដានីៈ	កាលហ្នឹងគាត់នៅវង ។

ជាតិៈ	បាទ!

ដានីៈ	បន្ទាប់ពីយើងបានជ័យជំនះទាំងស្រុងនៅខែ៤ ឆ្នាំ៩៩?

ជាតិៈ	អត់ទាន់ច្បាស់ទេ ទាល់តែសួរគេ សួរឯងទៀត ហ្នឹងជួរការមិនបានទេ ។

បូលីៈ	ខ្ញុំថាប្រហែលជាដើមខែ៣ ព្រោះតាម៉ុក គេចាប់ខ្លួនគាត់នៅ ។

ជាតិៈ	បើតាម៉ុក ចាប់ខ្លួនថ្ងៃណាថ្ងៃហ្នឹងហើយ មុនហ្នឹងទៀត យើងផ្តាច់ខ្លួនមុនហ្នឹងទៀត ។

ដានីៈ	ពេលដែលយើងបានជ័យជំនះហើយ ពេលហ្នឹងគេចាប់ផ្តើមរៀបចំរដ្ឋអំណាច ទាំងអន្លង់វែង និងត្រពាំងប្រាសាទ ។ ដូចថាអ៊ំមានគុណបំណាច់តាំងពីដឹកនាំកំលាំង ដល់ពេលហ្នឹងខាងរដ្ឋាភិបាលគេរៀបចំ គេចាត់តាំងអ៊ំយ៉ាងម៉េចដែរពេលហ្នឹង?

ជាតិៈ	កាលហ្នឹងបើត្រូវជាគោលនយោបាយ អាយុជីវិត តួនាទី ទ្រព្យរបស់ ខ្ញុំបានផ្កាយមួយនឹងគេដែរ ដូចលោកឃឹម ដាន់ណា អីចឹងដែរ តែខ្ញុំគិតថាចាស់ហើយ ហើយខ្ញុំគិតថាបុណ្យសក្តិដូចលែងចង់បាន ចង់បានដីធ្លីធ្វើស្រែ ចំការ ហើយនឹកថាដើម្បីបានដីធ្លីហ្នឹងទៅ ក៏សុំបង១ធ្វើចៅហ្វាយស្រុក ធ្វើអភិបាលស្រុក គាត់ក៏ណែនាំខ្ញុំថាធ្វើអភិបាលស្រុកតិចថាសតិអារម្មណ៍ ខ្ញុំថាសតិអារម្មណ៍យ៉ាងម៉េចឯកឧត្តម ។ សតិអារម្មណ៍វាខុសគោលនយោបាយ

របស់រដ្ឋាភិបាល ព្រោះរដ្ឋាភិបាលពិសេសបក្សប្រជាជនជាតួនាទីប៉ុណ្ណា ទុកឲ្យប៉ុណ្ណឹង ខ្ញុំថា ខ្ញុំទទួលខុសត្រូវ ខ្ញុំអត់មានបញ្ហាទេ ធ្វើសតិអារម្មណ៍ខ្ញុំប្រហែល៣ដង ជាមួយបងជាសារ៉ែន, បងមាស សុភា ។ ជាតិ អង្គុយកម្មវិធីប្រយ័ត្នខឹង ធ្វើចៅហ្វាយស្រុកស្មើរសក្តិ៣ ខ្ញុំអត់គិតអីចឹងទេឯកឧត្តម ខ្ញុំគិតតែរឿងដីស្រែ ដីចំការព្រោះខ្ញុំចាស់ហើយ គិតត្រូវមែន ចាស់បើនៅទល់ឥឡូវទន់ប៉ុណ្ណោះធ្វើអត់កើតទេ ។

បូលីៈ គេចង់ឲ្យអ៊ំធ្វើអីវិញ?

ជាតិៈ គេចង់ឲ្យធ្វើទាហានស្មើរនឹងផ្កាយ១ ។

ដានីៈ កាលពីឆ្នាំ៩៩ ផ្កាយ១?

ជាតិៈ ៩៩អី ចង់និយាយពីគោលនយោបាយដែលត្រូវទទួលស្គាល់ ។

បូលីៈ គេឲ្យផ្កាយ១តាំងពីហ្នឹងមក?

ជាតិៈ បាទ! ដល់ខ្ញុំធ្វើស្រុកវាត្រូវសក្តិ៣ ស្មើរនឹងសក្តិ៣ ហើយឋានៈស្មើរនឹងអនុមន្ត្រី ។

ដានីៈ អភិបាលស្រុកត្រឹមអនុមន្ត្រីទេ?

ជាតិៈ បាទ! អនុមន្ត្រី ។

ដានីៈ ដល់យើងផ្កាយ១?

ជាតិៈ ឧត្តមមន្ត្រី ។ ខ្ញុំសុខចិត្តថាមិនបាច់អីទេ អនុមន្ត្រីក៏បានដែរ ខ្ញុំយុទ្ធសាស្ត្រខ្ញុំចង់បានស្រែ ចង់បានចំការ ហើយចង់បាននៅជួបជុំក្រុមគ្រួសារ វាអីចឹង ខ្ញុំនឹកឃើញឆ្អែតហើយ ។

ដានីៈ ដល់ពេលអ៊ំចង់បានធ្វើជាអភិបាលស្រុក កាលហ្នឹងអ៊ំជា កែវ អត់ទេ?

ជាតិៈ គាត់ធ្វើទាហាន ឥឡូវគាត់ផ្កាយ២ គាត់នៅទាហានទល់ឥឡូវ ឥឡូវគាត់រងភូមិភាគ ។ ខ្ញុំបើធ្វើក៏រងភូមិភាគដែរ អីចឹងឯង ។

បូលីៈ តាម៉ុក គេចាប់ខ្លួនគាត់នៅខែ៣ ឆ្នាំ៩៩ អីចឹងការវៃចូលមកប្រហែលជាក្នុងខែ២ ។

ជាតិៈ ខែ១-២ហ្នឹង ។

បូលីៈ អ៊ំវៃពីខាងនេះ អ៊ំដាន់ណា វៃពីខាងនោះ ។

ជាតិៈ បាទ!

បូលីៈ វៃទប់គ្នា ។ ដល់តាម៉ុក ទៅណាអត់រួចឡើងច្រកជាំទៅភូណាយទៅ ។

ដានីៈ មួយទៀតចុងក្រោយ ទាក់ទងនឹងការបង្កើតជារដ្ឋបាលភូមិ-ឃុំ ហើយនិងស្រុកត្រពាំងប្រាសាទ ដូចអ៊ំជាអភិបាលស្រុកនេះមុនដំបូងគេបំផុតចាប់ផ្តើមមក យើងចាប់ផ្តើមរៀបចំយ៉ាងម៉េចទៅ?

ជាតិៈ កាលនោះរៀបចំ បង១ខាងលើទេថា ឲ្យខ្ញុំនេះខាងព្រះវិហារ ហើយអន្លង់វែងទៅខាងសៀមរាប អត់មានឯកសារទេតែការពិគ្រោះគ្នាអីចឹង ហើយខ្ញុំគិតថាចង់ឲ្យនៅជុំ តែសៀមរាបឈ្មោះគេល្បីណាស់ ថាបាននៅសៀមរាបនឹងគេ ខេត្តសៀមរាបនឹងគេកុំនៅខេត្តព្រះវិហារ ។ ការនិយាយគ្នាគ្មានអីមានតែខ្ញុំគាត់និយាយ ដល់ហើយខ្ញុំក៏សំរេចចិត្តអីចឹងបង១អត់ថាម៉េចទេស្រេចលោកឯង ទៅណាក៏បាន អីចឹងក៏សំរេចថានៅខេត្តសៀមរាប ។ ដល់អីចឹងក៏រៀបចំ តាមភូមិ-ឃុំ-ស្រុក ហើយកាលនោះលំបាកឈ្មោះ អត់មានឈ្មោះមានតែលេខ នាំគ្នាពិគ្រោះដាក់ឈ្មោះនេះ ទួលចារ តាសេក បេះតែខំដាក់ ចុះមានឈ្មោះអីដាក់ មានស្ពានព្រៃវាលណា៎ នៅម្តុំ១ កាលហ្នឹងដាក់ឈ្មោះតាមហ្នឹង ខ្ញុំរៀបចំដាក់ឈ្មោះ៦ឃុំ រកឈ្មោះដាក់មិនបាន រៀបចំបានតែ៤-៥ឃុំ ។ អន្លង់វែងតែ៥ឃុំទេ ខ្ញុំបាន៦ ។

បូលីៈ អ៊ឹអ្នកដាក់ឈ្មោះទាំងអស់ហ្នឹងប្តូយ៉ាងម៉េច?

ជាតិៈ ថាខ្ញុំក៏បាន តែខ្ញុំផ្តួចផ្តើមថាដាក់ម៉េចសម ។

បូលីៈ មានឃុំដែលកើតតាំងពីដើមមកទេ?

ជាតិៈ អត់ទេ កើតត្រឹមខ្ញុំហ្នឹង កើតត្រឹមខ្ញុំរដ្ឋាភិបាល ។

ដានីៈ ចុះត្រពាំងប្រាសាទដែលយើងដាក់ឈ្មោះស្រុកត្រពាំងប្រាសាទរាល់ថ្ងៃ ដាក់ជំនាន់អ៊ឹប្តូមានមុនហ្នឹង?

ជាតិៈ អត់មានទេ គ្រាន់តែដើរមកជួបត្រពាំង ឃើញប្រាសាទក៏ត្រពាំងប្រាសាទទៅ ។

បូលីៈ ប្រាសាទនៅណា?

ជាតិៈ ប្រាសាទនៅនោះ ប្រាសាទតូច ។

បូលីៈ ក្បែរវត្តហ្នឹង?

ជាតិៈ បាទ! ក្បែរវត្ត ។ ក៏ដាក់អីចឹងទៅ ឈ្មោះសមហេតុ សមផលដែរ ខ្ញុំអ្នកស៊ីញ៉ោរវៃត្រាទៅចេញអនុក្រិតមកភូមិ-ឃុំហ្នឹង ។ និយាយដល់កន្លែងហ្នឹងអួតពេក ។

ដានីៈ អត់អីទេ នេះជាការពិត ជាប្រវត្តិសាស្ត្រហើយជាការពិត ។ ត្រពាំងប្រាសាទហ្នឹងយើងចាប់ផ្តើមហៅមែនទែនពេលដែលអ៊ឹចាប់ផ្តើមសមាហរណកម្មហើយ យើងបង្កើតជាស្រុក ។ ពីមុនមកយើងអត់ហៅអីចឹងទេ?

ជាតិៈ កាលនោះហៅ៨០២ ។ តាឡឿន ៨០២ ។

ដានីៈ អីចឹងម្តុំត្រពាំងប្រាសាទយើងហៅ៨០២ កងតាឡឿនទេ ។

ជាតិៈ បាទ! ៨០២ ។

ដានីៈ ទាល់តែយើងសមាហរណកម្មហើយបានហៅត្រពាំងប្រាសាទ?

ជាតិៈ	បាទ!

ដានីៈ	អីចឹងយើងចាប់ផ្ដើមដំបូងមុនគេយើងដាក់ស្រុកត្រពាំងប្រាសាទ ហើយយើងបង្កើតជាឃុំ៦ ដំបូងឃុំអីគេខ្លះទៅ? ឃុំទី១?

ជាតិៈ	ដំបូងឃុំទី១យើងហៅឃុំត្រពាំងប្រាសាទ ឃុំទី២ ឃុំបាគលូង ឃុំទី៣ ឃុំទំនប់ដាច់ ឃុំទី៤ ព្រះប្រឡាយមានឈ្មោះតាំងពីដើមមក ។

ដានីៈ	មានឈ្មោះហ្នឹង ឈ្មោះអីគេ?

ជាតិៈ	ឈ្មោះព្រះប្រឡាយ ប្រកព្រះប្រឡាយ ។

ដានីៈ	ប្រកព្រះប្រឡាយមានឈ្មោះតាំងពីដើមមក?

ជាតិៈ	ភ្នំដូចឆកអីចឹង ភ្នំដូចប្រក ដូចផ្លូវ ចាស់ៗពីដើមគាត់ថាបរទេះបានតាមហ្នឹង ។

ដានីៈ	ព្រះប្រឡាយហ្នឹងយើងហៅតាមគេទេ ពេលដែលយើងមកឈរជើងនៅហ្នឹងកាល៧៩-៨០ហ្នឹងមានឈ្មោះព្រះប្រឡាយហើយ ។

ជាតិៈ	មានទាំងដែនទីទៀត ហើយនិងបាគលូងក្នុងដែនទី អីចឹងយកអាហ្នឹងទៅ ។ ផ្លាវ សុទ្ធតែឈ្មោះក្នុងដែនទី យើងយកក្នុងដែនទីដដែល ។

ដានីៈ	មានឃុំត្រពាំងប្រាសាទ, ឃុំទំនប់ដាច់, ឃុំបាក់អន្លង់, ឃុំព្រះប្រឡាយ ។

ជាតិៈ	អូរស្វាយ ។

ដានីៈ	អូស្វាយ ហើយនិងផ្លាវ ។ តែអូរស្វាយមានឈ្មោះគេតាំងពីដើមមកអត់?

ជាតិៈ	អត់មានទេ អូរហ្នឹងមានដើមស្វាយ៣ដើម គេទៅតាំងភូមិនៅហ្នឹង ហើយដាក់ឈ្មោះអូរស្វាយ ។

ដានីៈ	អូរមានដើមស្វាយ៣ដើម ។

ជាតិៈ	បាទ! ស្វាយចាស់ពីដើម ។

ដានីៈ	បើផ្លាវភូមិគេពីដើមមក?

ជាតិៈ	តាំងពីជំនាន់សង្គមចាស់ ។

ដានីៈ	មានមនុស្សរស់នៅក្នុងភូមិហ្នឹង?

ជាតិៈ	អត់ទេ មានតែដី មានដើមស្វាយ ដើមអំពិល ក្រសាំង ។

បូលីៈ	អីចឹងភូមិចាស់៣ ឃុំថ្មី៣ ដែលឈ្មោះ?

ជាតិៈ	បាទ!

បូលីៈ	ដែលមានតាំងពីដើមមកមាន៣ហើយ មានផ្លាវ, ព្រះប្រឡាយ ហើយនិងបាក់អន្លង់ ហើយអឹបង្កើតថ្មីថែម៣ទៀត មានត្រពាំងប្រាសាទ, ទំនប់ដាច់ ហើយនិងអូរស្វាយ?

ជាតិៈ បាទ!

បូលីៈ ដែលជាឃុំថ្មី?

ជាតិៈ បាទ!

ដានីៈ ទំនប់ដាច់យ៉ាងម៉េចបានជាអីដាក់ឈ្មោះទំនប់ដាច់ ។

ជាតិៈ កាលហ្នឹងចេះធ្វើទំនប់ហើយវាដាច់ទំនប់ ទំនប់ដាច់ៗទៅ ។

ដានីៈ ទំនប់ហ្នឹងធ្វើឆ្នាំណា?

ជាតិៈ ធ្វើយូរហើយតាំងពីជំនាន់មុន៩០ ។

ដានីៈ ពីណាអ្នកផ្តួចផ្តើមធ្វើហ្នឹង?

ជាតិៈ តា០៥ ។

ដានីៈ ទំនប់ហ្នឹងទំនប់របស់តា០៥ អ្នកផ្តួចផ្តើមធ្វើ?

ជាតិៈ បាទ! ចុះយើងអត់ទឹក ។

បូលីៈ ធ្វើពេលដែលយើងចុះពីលើភ្នំមកទេ?

ជាតិៈ ចុះមកនៅយើងធ្វើ ។

បូលីៈ ឆ្នាំកៅសិបហើយ ។

ជាតិៈ ធ្វើ ។

ដានីៈ យើងដូចអស់ ។

ជាតិៈ ខ្ញុំអស់ចិត្ត អស់ថ្វើម ឈឺស្មាតែខំ ខ្ញុំនិយាយការពិត ខ្ញុំអត់និយាយលើសខ្វះ ។

បូលីៈ មែនទែនដោយសារចំណាយពេលអីច្រើនពេក ខ្ញុំចង់ដឹងលំអិតដល់ការកកើតភូមិ-ឃុំដែរ បើសិនថ្ងៃក្រោយខ្ញុំមិនច្បាស់កន្លែងណា សរសេរទៅឆកល្ងែងកន្លែងណា ចង់មកសុំសួរអីបន្ថែម អំពីការកកើតស្រុកត្រពាំងប្រាសាទ និងភូមិ-ឃុំនៅទីនេះ ។ ចេញពីណា អ្នកណាអ្នកបង្កើតឈ្មោះ ។

ដានីៈ អ៊ំកាន់ជាអភិបាលស្រុកនេះពីឆ្នាំណាដល់ឆ្នាំណាដែរ?

ជាតិៈ ដូចឆ្នាំ២០០០ខ្ញុំតែងតាំង ។ ឆ្នាំ២០០០-២០០៥ ។ ដល់២០០៥ទៅធ្វើអភិបាលរងខេត្ត ។

ដានីៈ អីចឹងអ៊ំកាន់នៅនេះ២០០០-២០០៥ ។

ជាតិៈ និយាយរួមកាន់រហូតដល់ផ្លូវការ ។

ដានីៈ ផ្លូវការពី២០០០-២០០៥?

ជាតិៈ បាទ!

ដានី៖ ២០០៥?

ជាតិ៖ ខ្ញុំធ្វើរងខេត្ត ។

ដានី៖ ទៅធ្វើអភិបាលរងខេត្ត?

ជាតិ៖ បាទ!

ដានី៖ ដល់សព្វថ្ងៃក៏អ៊ំនៅតែអភិបាលរងខេត្តដែរ?

ជាតិ៖ អត់ទេ មកកាន់ក្រុមប្រឹក្សាបាន៥ឆ្នាំហើយ ។

បូលី៖ ក្រុមប្រឹក្សាខេត្ត?

ដានី៖ អ៊ីចឹងពីឆ្នាំ២០០៥ដល់ឆ្នាំពីរពាន់ប៉ុន្មានដែលអ៊ំជាអភិបាលរងខេត្ត?

ជាតិ៖ ឥឡូវក្រុមប្រឹក្សាកើតពីថ្ងៃណា ដល់កើតក្រុមប្រឹក្សាក៏ផ្ទេរ ។

បូលី៖ បោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់២០០២ ។

ដានី៖ ខេត្ត ។

បូលី៖ ដល់ពេលខេត្តកើតបោះក្រោយទៀត ។

ជាតិ៖ ខ្ញុំមិនបានចាំ ។ ដល់ពេលហើយខ្ញុំផ្ទេរមកហ្នឹង ក្របខណ្ឌដើមនៅក្រសួងមហាផ្ទៃ ដល់ពេលផ្ទេរមកក្រុមប្រឹក្សា ។ អភិបាលរង២នាក់ មានតាឃីន ធិន ហើយខ្ញុំ តាឃិន ធិន គាត់ទី១ ខ្ញុំទី២ ។ អត់មានប្រធាន និងអនុទេ មានតែប្រធាន ។

ដានី៖ ជំនាន់ឯកឧត្តម ពេជ្រ សុឃិន?

ជាតិ៖ បាទ! ពេជ្រ សុឃិន គាត់អភិបាល ។

ដានី៖ អ៊ំកូនចៅប៉ុន្មាននាក់ដែរ?

ជាតិ៖ ខ្ញុំកូនមែនទែន៤ ។ ដល់ពេលអត់កូនប្រុស សុំកូនប្រុសមួយទៀតឡើង៥ ។

ដានី៖ អ៊ំស្រីគាត់ឈ្មោះអីដែលអ៊ំ?

ជាតិ៖ ខ្ញុំគ្រួសារស្លាប់បាត់ហើយ គ្រួសារស្លាប់ពីរដង ម្ដាយនាងនេះឈ្មោះ ហម ស៊ីណាត គាត់នៅកំពង់ចាម នៅកងមាស ស្លាប់បាត់ហើយឆ្នាំ៩៣ ។

ដានី៖ ចុះអ៊ំស្រីរាល់ថ្ងៃ?

ជាតិ៖ យកមុនហ្នឹងស្លាប់ទៀត ឈ្មោះទូច សារ៉ុម បានកូនមួយ ។ ដល់ឥឡូវហ្នឹងមិនទាន់យកអីមែនទែនទេគ្រាន់តែថាត្រៀម ដល់គេចាស់ពេកគេឈឺប្រហែលឯង គេក៏ទៅផ្ទះគេ ឯងក៏នៅផ្ទះឯង ។

ដានី៖ អ៊ីចឹងពួកខ្ញុំអរគុណអ៊ំច្រើនមែនទែន ដែលចំណាយពេលទាំងឈឺផ្ដល់ព័ត៌មាន ព័ត៌មាននេះសំខាន់មែនទែន ខ្ញុំអរគុណច្រើនអ៊ំ ។

ដាតិៈ		បាទ! ខ្ញុំក៏អរគុណ ជូនពរក្មួយទាំងអស់ឲ្យមានសុខភាពល្អ ជោគជ័យការងារ ។
ដានីៈ		អរគុណច្រើនអ៊ី ។

ចប់